**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូត

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

គាត់តែងឡើងដោយ

និស្សិតឈ្មោះ៖ **សុខា ពិគុណបុត្តី**

**ញ៉់ប្រុស សុគន្ធថារី**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឃឹម គីរី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២១

ចូលឆ្នាំសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតឆ្នាំទី៤ សិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាមានសេចក្តីសោមនស្សជាទីបំផុត ដែលមានឱកាសបានសរសេរនូវសារណាមួយនេះឡើង។ ក្នុងដំណើរការសិក្សារយៈពេលបួនឆ្នាំកន្លង យើងខ្ញុំពិតបានទទួលគុណូបការៈអំពីអ្នកមានគុណជាច្រើន។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណនិងសម្តែងសេចក្តីកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះវត្តមានរបស់បុព្វការីជនទាំងឡាយនោះ។ ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណនិងសម្តែងនូវភាពកត្តញ្ញូតាធម៌ជូនចំពោះ លោកឪពុកអ្នកម្តាយ ជាទីគោរព។ តាំងតែពីថ្ងៃចាប់កំណើតរបស់យើងខ្ញុំ លោកទាំងពីរមានគុណូបការៈជាពនពេក។ លោកឪពុកអ្នកម្តាយបានផ្តល់កំណើតមកដល់យើងខ្ញុំចិញ្ចឹមបីបាច់ថែរក្សាតាំងតែពីកុមារភាពផ្តល់ទីជម្រកកក់ក្តៅផ្តល់ម្ហូបអាហារនិងទំនុកបម្រុងកូនៗឱ្យមានឱកាសបានសិក្សារៀនសូត្រពីថ្នាក់មត្តេយ្យរហូតដល់ថ្ងៃបញ្ចប់ឆ្នាំសិក្សានៃថ្នាក់សាកលវិទ្យាល័យដោយលោកផ្គត់ផ្គង់មិនឱ្យខ្វះចន្លោះឡើយ។ ក្រៅអំពីការទំនុកបម្រុងផ្នែករូបរាងកាយនិងសម្ភារៈអ្នកមានគុណទាំងទ្វេនៅគាំពារខាងផ្នែកសតិបញ្ញាស្មារតីចំពោះយើងខ្ញុំផងដែរ ដោយលោកមែងតែអប់រំទូន្មានប្រៀនប្រដៅឱ្យកូនក្លាយជាកូនកត្តញ្ញូកត្តវេទីតាធម៌មិត្តជាទីស្រលាញ់រាប់អានសិស្សនិស្សិតគម្រូនិងជាធនធានមនុស្សដ៏ល្អប្រពៃសម្រាប់សង្គមជាតិយើង។ ជាកិត្តិយស យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណជាអនេក ចំពោះឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចណ្ណា** សាកលវិទ្យាធិការរងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រចារ្យនិងមន្ត្រីរាជការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់។ ក្រោមការដឹកនាំប្រៀបប្រដៅនិងបង្ហាត់បង្រៀនអំពីលោកអ្នកទាំងឡាយនាំឱ្យសិស្សានុសិស្សរួមទាំងយើងខ្ញុំទាំងពីរទទួលបានចំណេះដឹងទាំងមុខវិជ្ជាឯកទេសក៏ដូចជាការអប់រំទូទៅយ៉ាងពេញលេញសម្រាប់ជាស្ពានចម្លងទៅថ្ងៃអនាគត។ ជាពិសេស យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកសាស្ត្រចារ្យណែនាំ **ឃឹម គីរី** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកធ្វើការផ្តល់ជាមតិណែនាំ ប្រឹក្សានិងកែតម្រូវដល់យើងខ្ញុំ ក្នុងដំណើរការសិក្សាស្រាវជ្រាវនូវសារណាមួយនេះឡើងតាំងតែពីថ្ងៃចាប់ផ្តើមរហូតដល់ថ្ងៃបញ្ចប់ដោយជោគជ័យ។

ជាមួយនឹងការរៀបរាប់ជាសង្ខេបខាងលើមកហើយ យើងខ្ញុំពិតទទួលបានសេចក្តីចម្រើនឧបការគុណនិងគុណានុភាពដោយសារវត្តមាននៃលោកទាំងអស់ចាំជ្រំជ្រែងថែរក្សានិងការពារ។ ហេតុនេះហើយ ជាចុងបញ្ចប់នៃសេចក្តីថ្លែងអំណរគុណ យើងខ្ញុំជាសិស្សនិស្សិតសូមធ្វើការបួងសួងដល់វត្ថុសក្តិសិទ្ធិនិងទេវតាទាំងឡាយក្នុងលោកនេះឱ្យប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណអស់លោក លោកស្រីទាំងឡាយឱ្យជួបតែសេចក្តីសុខចម្រើនសុភមង្គលសុខភាពល្អ ព្រមទាំងមានអាយុយឺនយូរនិងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានចាប់អារម្មណ៍ទៅលើប្រធានបទពាក់ពន្ធ័ទៅនឹងមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ កាលពីសិក្សាទី២មកម្ល៉េះ។ ពេលដែលយើងខ្ញុំចូលបណ្ណាល័យដើម្បីស្វែងរកឯកសារដែលពាក់ព័ន្ធទៅនឹងមុខវិជ្ជានេះ គឺមានការលំបាកដោយសារពុំសូវមានឯកសារបកប្រែជាភាសាខ្មែរ តែដោយមានចំណង់ចំណូលចិត្តមុខវិជ្ជានេះ ទើបធ្វើឱ្យមានការចាប់អារម្មណ៍ចង់សរសេរប្រធានបទទាក់ទងនឹងមុខវិជ្ជានេះ។ ដោយឡែកងាកទៅមើលនៅប្រទេសកម្ពុជាយើង ទំនាក់ទងអន្តរជាតិយើងមានជាយូរណាស់មកហើយ ដែលជាមូលហេតុដែរយើងខ្ញុំសម្រេចចិត្តយកមុខវិជ្ជានេះមកសិក្សា។ ជាទូទៅ ពេលដែលអ្នកឮថាការទូត គឺតែងតែយល់ថាជាអ្នកដែរធ្វើការតំណាងឱ្យរដ្ឋ ប៉ុន្តែមិនយល់ច្បាស់ថា តើការទូតមានតួនាទីអ្វី?ពេលខ្លះអ្នកអាចនឹងឆ្ងល់ថាហេតុអ្វីបានជាមានស្ថានទូត? ហើយហេតុអីបានជាគេឱ្យសិទ្ធិទៅពួកគេច្រើនជាងពលរដ្ឋម្ចាស់ផ្ទះទៀត?

មូលហេតុមួយទៀតដែលធ្វើឱ្យយើងខ្ញុំផ្តោតទៅលើប្រធានបទខាងលើដោយសារ តែការពីពេលដែលរៀនមុខវិជ្ជានេះមានមេរៀនដែលពាក់ព័ន្ធនឹងពាក្យអភ័យឯកសិទ្ធិប៉ុន្តែនៅពេលទៅបណ្ណាល័យស្រាវជ្រាវពុំមានឯកសារពាក់ព័ន្ធ ក្រោយពីពិភាក្សាគ្នាជាមួយលោកគ្រូសាស្ត្រាចារ្យណែនាំក៏សម្រេចចិត្តសរសេរប្រធានបទនេះ។ ដោយសារកន្លងមកពុំសូវមាននិស្សិតចាប់អារម្មណ៍ខ្លាំងទៅលើប្រធានបទនេះ ពេលពួកគាត់ឮទាក់ទងនឹងពាក្យការទូតគឺតែងតែនិយាយធ្លាប់ឮតែមិនយល់ថាជាអ្វី? ដោយសារកត្តាខាងលើនេះយើងខ្ញុំក៏សម្រេចចិត្តយកប្រធានបទបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អ្នកការទូត មកធ្វើជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។ ដោយប្រធានដែលយើងខ្ញុំយកមកបកស្រាយនេះ ពឹងផ្អែកទៅលើឯកសារជាភាសាបរទេសច្រើនជាងភាសាខ្មែរដោយមូលហេតុពុំសូវមានឯកសារជាភាសាខ្មែរ។

យើងខ្ញុំសង្ឃឹមថា សារណារបស់យើងខ្ញុំអាចជាជំនួយដល់ការសិក្សាផ្នែកទំនាក់ទំនងអន្តរជាតិ ដែលជាពិសេសទៅនឹងការទូត។ យើងខ្ញុំរំពឹងថាវាអាចនឹងជាឯកសារមួយសម្រាប់និស្សិតនិងមិត្តអ្នកអានក្នុងការសិក្សាស្រាវជ្រាវលើផ្នែកទំនាក់ទំនងអន្តរជាតិនេះ។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំជឿស្នាដៃនេះនៅមានចំណុចខ្វះខាត យើងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចនូវការរិះគុណក្នុងន័យស្ថាបនា។

សូមអរគុណ!

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ **១**

## ជំពូកទី ១

## សញ្ញាណទូទៅនៃការទូត

**១. ប្រវត្តិសាស្ត្រនៃទំនាក់ទំនងការទូត** ........ ៣

**២. ការស្ថាបនាទំនាក់ទំនងការទូត** ........ **៥**

២. ១. បេសកកម្មការទូត ........ ៧

២. ២. មុខងារនៃបេសកកម្មការទូត ........ ៨

២. ២. ១. មុខងារតំណាង ........ ៨

២. ២. ២. មុខងារការពារ ........ ៨

២. ២. ៣. មុខងារផ្តល់ព័ត៌មាន ........ ៩

២. ៣. សមាជិកនៃបេសកកម្មការទូត ........ ៩

២. ៣. ១. សញ្ជាតិ ........ ១០

២. ៣. ២. ប្រមុខនៃបេសកកម្ម ........ ១១

២. ៣. ៣. សមាជិកនៃបុគ្គលិកមន្ត្រីការទូត ........ ១២

២. ៣. ៤. សមាជិកនៃក្រុមរដ្ឋបាលនិងបច្ចេកទេស ........ ១៣

២. ៣. ៥. សមាជិកនៃក្រុមបុគ្គលិកសេវាកម្ម ........ ១៣

**៣. ការបញ្ចប់ទំនាក់ទំនងការទូត** ........ **១៤**

## ជំពូកទី ២

## បុព្វសិទ្ធិការទូត

**១. និយមន័យ** ........ **១៦**

**២. ចំពោះទីស្ថាននៃបេសកកម្ម** ........ **១៦**

២. ១. ការជួយសម្រួល ........ ១៦

២. ២. ភាពមិនអាចបំពារបំពានបាន ........ ១៦

**៣. ចំពោះដំណើរការនៃបេសកកម្ម** ........ **១៨**

៣. ១. ការជួយសម្រួល ........ ១៨

៣. ២. ភាពមិនអាចបំពារបំពានបាន ........ ១៨

**៤. ចំពោះឯកត្តជនភាពនៃសមាជិកបេសកកម្ម ........................................ ២០**

៤. ១. ការជួយសម្រួល .................................................................... ២០

៤. ២. សេរីភាពក្នុងការធ្វើដំណើរ ...................................................... ២១

៤. ៣. ភាពមិនអាចបំពារបំពានបាន .................................................... ២២

៤. ៣. ១. រូបរាងកាយ ............................................................ ២២

៤. ៣. ២. លំនៅស្ថាន ............................................................ ២៣

៤. ៤. លិខិតឆ្លងដែនការទូត ............................................................ ២៣

៤. ៥. សមាជិកគ្រួសារ ...................................................................... ២៥

**៥. មន្ត្រីការទូតមានសញ្ជាតិរដ្ឋម្ចាស់ផ្ទះ .................................................... ២៥**

**៦. សុពលភាពនៃបុព្វសិទ្ធិ ...................................................................... ២៥**

## ជំពូកទី ៣

## អភ័យឯកសិទ្ធិការទូត

**១. និយមន័យ .................................................................................. ២៧**

**២. ចំពោះទីស្ថាននៃបេសកកម្ម .............................................................. ២៧**

**៣. ចំពោះដំណើរការនៃបេសកកម្ម .......................................................... ២៩**

៣. ១. អភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការរដ្ឋម្ចាស់ផ្ទះ ............................................ ២៩

៣. ២. ទស្សនៈយល់ច្រលំមួយចំនួនចំពោះការផ្តល់អភ័យឯកសិទ្ធិការទូត ............................ ៣១

**៤.អភ័យឯកសិទ្ធិរបស់ភ្នាក់ងារដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះនិងសមាជិកគ្រួសារ ក្រុមបុគ្គលិកដទៃទៀត នៃបេសកកម្មការទូត ........................................ ៣២**

**៥. ភារកិច្ចគោរពច្បាប់រដ្ឋម្ចាស់ផ្ទះនិង វិធានការ** Persona Non Grata ..................... **៣៣**

**៦. សុពលភាពនៃអភ័យឯកសិទ្ធិ .............................................................. ៣៥**

**សេចក្តីសន្និដ្ឋាន ........................................................................... ៣៧**

**អនុសាសន៍ ................................................................................. ៣៩**

**សន្ទានុក្រម**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ទំនាក់ទំនងការទូត គឺជាសិល្បៈឬការអនុវត្តនូវការចរចារដោយសន្តិវិធីដែលរដ្ឋនានានៅក្នុងពិភពលោកយកមកប្រើប្រាស់ក្នុងការដោះស្រាយវិវាទ ដែលកើតមានឡើងក្នុងអនុវត្តប្រតិបត្តិការបរទេសរវាងរដ្ឋ និងរដ្ឋ។ ពីសម័យបុរាណ ការអនុវត្តការទូតគឺជាការបញ្ជូនអ្នកតំណាងស្របច្បាប់ណាម្នាក់ ទៅកាន់ទឹកដីនៃរដ្ឋមួយ ហើយអ្នកតំណាងនោះទៀតសោតត្រូវបានគេហៅថាជាអ្នកនាំសារ ជាទូត ឬជាបេសកជន ដែលដើមឡើយមានតួនាទីពាំនាំខ្លឹមសារចរចារឱ្យដល់អ្នកដឹកនាំ នៃភាគីម្ខាងទៀតតែប៉ុណ្ណោះ។ មុខងារនេះហាក់ដូចជាប្រឈមនឹងគ្រោះថ្នាក់ជាអនេក ចាប់ផ្តើមពីការធ្វើដំណើរវែងឆ្ងាយចូលទៅដល់ទឹកដីនៃគូរជំលោះ និងការសម្រេចចូលគាល់នឹងព្រះមហាក្សត្រ ដោយហេតុថាអំឡុងរាប់ពាន់ឆ្នាំមុនដែនដីនីមួយៗមានរបៀបគ្រប់គ្រងជារាជាណាចក្រ ដែលមានព្រះមហាក្សត្រជាអ្នកសម្រេចរាល់កិច្ចការតូចធំនិងត្រូវបានគេគោរពតម្កើង។ កាយវិការពាក្យសំដី ឬហួតដល់ខ្លឹមសារនៃការចរចារតែងតែមានភាពប៉ះទង្គិចនិងចាត់ទុកជាការប្រមាថដោយខានពុំបាន ហេតុនេះអ្នកតំណាងសម័យបុរាណអាចនឹងមិនមានជីវិតសម្រាប់ដឹកនាំសារត្រលប់ទៅវិញផង។ ទោះបីជាយ៉ាងនេះក្តី ក៏នៅមានក្រុមមនុស្សក្រុមរដ្ឋ ដែលហាក់ស្វែងយល់ពីគុណតម្លៃនិងសារៈសំខាន់នៃអ្នកនាំសារនេះផងដែរ។ ដោយពួកគេចាប់ផ្តើមផ្តល់អតិភាពដល់អ្នកដែលជាតំណាង ព្រោះពួកគេយល់ថាការទទួលបានសារឬដោះដូរសារមានភាពចាំបាច់ជាងការសម្លាប់អ្នកបញ្ជូនសារ។ ជាមួយគ្នានេះដែរ លោក Harold Nicolson (១៩៩៨) គាំទ្រយ៉ាងពេញលេញចំពោះភាពចាំបាច់នៃអ្នកការទូតដោយលោកបានសរសេរក្នុងសៀវភៅសារៈសំខាន់នៃអភ័យឯកសិទ្ធិការទូត របស់លោកថា "...មិនមានការចរចារណាមួយអាចសម្រចបានដោយជោគជ័យឡើយ ប្រសិនបើអ្នកការទូតត្រូវបានគេសម្លាប់គ្រប់ពេល ដែលគេបានមកដល់(ទឹកដីនៃរដ្ឋដទៃ)។ ហេតុនេះហើយ គោលការណ៍ទីមួយដែលត្រូវកំណត់ជាចាំបាច់គឺ អភ័យឯកសិទ្ធិការទូតនេះឯង។"

ជាការពិតណាស់ ទំនាក់ទំនងការទូតមានសារៈសំខាន់សម្រាប់ភាពចុះសម្រុងគ្នារវាងរដ្ឋនិងរដ្ឋ ដោយផ្អែកតាមការចរចាររកដំណោះស្រាយដោយសន្តិវិធី ព្រមទាំងរក្សាផលប្រយោជន៍របស់ភាគីទាំងសងខាង។ លើសពីនេះទៀត ការចរចារមួយប្រកបទៅដោយរលូន លុះត្រាតែមានអ្នកតំណាងល្អ ដែលមានសមត្ថភាពនិងសិទ្ធិគ្រប់គ្រាន់សម្រាប់បំពេញដំណើរការចរចារនោះ។ ហេតុដូច្នេះហើយ មូលដ្ឋានគ្រឹះសំខាន់បំផុតក្នុងការធ្វើទំនាក់ទំនងការបរទេសដោយជោគជ័យ គឺការផ្តល់នូវបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិពេញលេញនិងស្របច្បាប់ដល់អ្នកតំណាងផ្លូវការរបស់រដ្ឋ។ បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិការទូត គឺជាសិទ្ធិពិសេសទាំងឡាយណា ដែលរដ្ឋម្ចាស់ផ្ទះបានផ្តល់ឱ្យអ្នកតំណាងរបស់រដ្ឋដាក់ទូតក្នុងការបំពេញនូវបេសកកម្មនៅលើទឹកដីរបស់ខ្លួនដោយអ្នកតំណាងទាំងអស់នោះរួមមានមន្ត្រីការទូត ភ្នាក់ងារការទូតនិងបុគ្គលិកនៃតំណាងបេសកកម្ម។

ហេតុនេះហើយការសិក្សានិងយល់ដឹងឱ្យបានច្បាស់លាស់អំពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិការទូតមានសារៈសំខាន់ណាស់សម្រាប់សិស្សនិស្សិតដែលមានបំណងបំពេញមុខងារក្នុងក្របខ័ណ្ឌទំនាក់ទំនងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិហើយប្រធានបទនេះក៏ជាប្រយោជន៍ផងដែរក្នុងការយល់ដឹងអំពីសកម្មភាពការបទេសរវាងរដ្ឋសាមីនិងរដ្ឋដទៃទៀតនៅក្នុងប្រព័ន្ធអន្តរជាតិ។ ការស្វែងយល់ពីព្រំដែននៃសិទ្ធិនិងបុព្វសិទ្ធិ ថាតើបានស្ថិតក្នុងកម្រិតសមល្មមសម្រាប់បំពេញសកម្មភាពជាប្រយោជន៍រួម ឬលើសលុបដល់អាចឱ្យគេបម្រើប្រយោជន៍ផ្ទាល់ខ្លួន។ តទៅនេះ ការសិក្សាស្រាវជ្រាវរបស់ក្រុមនាងខ្ញុំនឹងផ្ដោតទៅលើបុព្វហេតុទូទៅនៃការទូត បុព្វសិទ្ធិអ្នកការទូត ព្រមទាំងអភ័យឯកសិទ្ធិរបស់ពួកគេផងដែរ ដោយចែកចេញជា ៣ ជំពូកសំខាន់ៗ។ នៅក្នុងជំពូកទី១ យើងនឹងសិក្សាទៅលើសញ្ញាណទូទៅនៃការទូត ដោយរួមមានប្រវត្តិសាស្ត្រនៃទំនាក់ទំនងការទូត ការចាប់ផ្ដើមទំនាក់ទំនងការទូតរវាងរដ្ឋនិងរដ្ឋនិងការបញ្ចប់ទៅវិញនូវទំនាក់ទំនងនេះ។ រីឯនៅក្នុងជំពូកទី២ យើងផ្ដោតទៅលើបុព្វសិទ្ធិរបស់ការទូតសំដៅសិក្សាអំពីសិទ្ធិរបស់ទីស្ថានបេសកកម្ម ដំណើរការបេសកកម្ម អ្នកតំណាងស្របច្បាប់ព្រមទាំងសមាជិកគ្រួសាររបស់ពួកគេនៅលើទឹកដីនៃរដ្ឋដាក់ទូត។ ជាចុងក្រោយអភ័យឯកសិទ្ធិនានា ដែលរដ្ឋដាក់ទូតផ្តល់ឱ្យចំពោះទីស្ថានបេសកកម្ម ដំណើរការបេសកកម្ម អ្នកតំណាងស្របច្បាប់ព្រមទាំងសមាជិកគ្រួសាររបស់ពួកគេនឹងត្រូវបានសិក្សានៅក្នុងជំពូកទី៣។

# ជំពូកទី ១
# សញ្ញាណទូទៅនៃការឆ្នោត

# ជំពូកទី ១

# សញ្ញាណទូទៅនៃការទូត

## ១. ប្រវត្តិសាស្ត្រនៃទំនាក់ទំនងការទូត

ដូចបានសិក្សាក្នុងសេចក្តីផ្តើម ទំនាក់ទំនងការទូតជាវិធីសាស្ត្រក្នុងការចរចារដោយសន្តិវិធីនិងជាប្រព័ន្ធសម្រាប់រក្សាទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ។ ប្រសិនបើមិនមានវិធីសាស្ត្រនេះ ប្រតិបត្តិការអន្តរជាតិជាច្រើននៅលើពិភពលោកនឹងត្រូវបានលុបបំបាត់ អង្គការអន្តរជាតិនឹងមិនមានវត្តមាន ហើយសកលលោកនឹងពោរពេញដោយសង្គ្រាមបង្ហូរឈាម។ ហេតុនេះហើយ ទើបវត្តមានរបស់ទំនាក់ទំនងការទូតមានសារៈសំខាន់ ពោលវាបានផ្តល់ឱកាសដល់បណ្តាប្រទេសមួយចំនួនធំអាចរស់នៅដោយចុះសម្រុងជាមួយគ្នា បើទោះបីជាការពាក់ស្បែកមុខដើម្បីផលប្រយោជន៍រាងៗខ្លួនក៏ដោយ ក៏ការអនុវត្តប្រព័ន្ធនេះអាចបញ្ចៀសសង្គ្រាម ដែលនាំតែសេចក្តីវិនាសអន្តរាយដល់សង្គមជាតិនិងប្រជាជាតិនៅលើសកលលោក។

បើយើងក្រឡេកមកមើល អំពីប្រវត្តិសាស្ត្រសម័យទំនើប គេតែងចាត់ទុក អ៊ីតាលីជាអ្នកត្រួសត្រាយផ្លូវដ៏សំខាន់មួយសម្រាប់ទំនាក់ទំនងការទូត ដោយសំអាងថាស្ថានទូតដំបូងបង្អស់ត្រូវបានបង្កើតឡើងនៅលើទឹកដីអ៊ីតាលីភាគខាងជើងនាសតវត្សរ៍ទី១៣។ មិនតែប៉ុណ្ណោះ ទំនៀមទម្លាប់ដែលគេប្រើប្រាស់ក្នុងការប្រតិបត្តិការទូតដូចជា ការផ្តល់ងារជាអគ្គរាជទូតដល់អ្នកតំណាង មានដើមកំណើតមកពីប្រទេសអ៊ីតាលី ហើយត្រូវបានគេយកមកប្រើប្រាស់ជាទូទៅនិងជាផ្លូវការក្នុងឆាកអន្តរជាតិរហូតមកដល់សព្វថ្ងៃនេះ។ ជាមួយគ្នានោះដែរ បណ្តារដ្ឋអធិបតេយ្យមួយចំនួនធំបានចាប់ផ្តើមទទួលស្គាល់នូវឋានៈពិសេសរបស់អ្នកការទូត។ ជាភាពចាំបាច់អ្នកការទូតទទួលបាននូវសិទ្ធិពិសេសក្នុងការរួចផុតពីការកាប់សម្លាប់ឬប្រមាថមាក់ងារ។ ពួកគេត្រូវចាត់ទុកជាភ្ញៀវកិត្តិយសរបស់រដ្ឋដែលគេបានស្ថិតនៅ ហើយការទំនាក់ទំនងរវាងជននោះនឹងរដ្ឋសាមីរបស់គេត្រូវបានការពារជាសម្ងាត់ផងដែរ។ លើសពីនេះ សេរីភាពពេញលេញរបស់ពួកគេក៏ត្រូវបានធានាពីសំណាក់រដ្ឋ ដែលបេសកជននោះបាននិងកំពុងបំពេញបេសកកម្មការទូត។

ចំពោះប្រទេសកម្ពុជាវិញការចងសម្ព័ន្ធភាពអន្តរជាតិជាមួយប្រទេសជិតខាងមានតាំងពីយូរលង់ណាស់មកហើយ គឺចាប់តាំងពីសម័យនគរភ្នំមកម្ល៉េះ។ យោងតាមឯកសារប្រវត្តិសាស្ត្ររបស់ចិនបុរាណ បានបញ្ជាក់ឱ្យដឹងថា ចក្រភពនគរភ្នំ ឬដែលហៅតាមសូរសំនៀងរបស់ចិនថានគរហ្វូណាននោះ បានប្រស្រ័យទាក់ទងជាមួយចក្រភពចិននិងឥណ្ឌា ដែលជាប្រទេសជិតខាងរបស់ខ្លួនទាំងតាមផ្លូវការទូត ទាំងខាងពាណិជ្ជកម្មយ៉ាងគគ្រឹកគគ្រេងតាំងតែពីសតវត្សរ៍ដំបូងនៃគ្រឹស្តសករាជមកម្ល៉េះ។ ទោះបីជាទំនាក់ទំនងការបរទេសនិងការគោរពទំនៀមទំលាបអន្តរជាតិនៅប្រទេសកម្ពុជា ក៏ដូចជានៅលើពិភពលោកមានជាយូរយារណាស់មកហើយក៏ច្បាប់ការទូតនៅពុំទាន់មានវត្តមានជាច្បាប់សរសេរឱ្យបានច្បាស់លាស់នៅឡើយទេ។

ទើបតែក្នុងសន្និបាតក្រុងវៀនឆ្នាំ ១៨១៥ គណៈកម្មការច្បាប់អន្តរជាតិ (International Law Commision) ចាប់ផ្តួចផ្តើមគំនិតប្រមូលផ្តុំនិងចងក្រងបុព្វសិទ្ធិទាំងឡាយរបស់អ្នកការទូតឱ្យក្លាយទៅជាច្បាប់សរសេរ។ ហើយប៉ុន្មានឆ្នាំបន្ទាប់ សេចក្តីព្រាងដំបូងបង្អស់របស់គណៈកម្មការច្បាប់អន្តរជាតិបានសម្រេចចេញជាផ្លូវការព្រមទាំងនៅឈរជាឫសគល់ដ៏សំខាន់សម្រាប់ច្បាប់ការទូត ដែលប្រជាជាតិបាននិងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១ ជាថ្ងៃដែលអង្គការសហប្រជាជាតិសម្រេចអនុម័តសេចក្តីព្រាងនេះក្នុងសន្និសិទរបស់ខ្លួនលើប្រធានបទកិច្ចពិភាក្សានិងអភ័យឯកសិទ្ធិការទូតនាទីក្រុងវៀន ប្រទេសអូទ្រីស។ ច្បាប់ការទូតត្រូវបានទទួលស្គាល់ស្របច្បាប់ ដោយមានឈ្មោះថាជា អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត (Vienna Convention on Diplomatic Relations) និងមានអនុភាពស្របច្បាប់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៤។ អស់រយៈពេលជាងកន្លះសតវត្សរ៍ អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត មានរដ្ឋហត្ថលេខីចំនួន ៦០ រដ្ឋ ហើយ១៩៣ប្រទេសបានផ្តល់សច្ចាប័នក្នុងការទទួលយកអនុសញ្ញានេះ។ ក្នុងនោះផងដែរ ប្រទេសកម្ពុជា បានសម្រេចសុំភ្ជាប់ខ្លួនទៅនឹងអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៦៥ ដែលហាក់មានភាពយឺតយ៉ាវបន្តិចបន្តួច ដោយហេតុថាប្រទេសកម្ពុជាបានចាប់ផ្តើមទំនាក់ទំនងការទូតពេញលេញជាមួយបណ្តាប្រទេសមួយចំនួនតាំងពីអំឡុងទសវត្សរ៍ឆ្នាំ១៩៥០មកម្ល៉េះ។ ពោលកម្ពុជាផ្តើមទំនាក់ទំនងការទូតផ្លូវការជាមួយសហរដ្ឋអាមេរិកនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២ចាប់ពីពេល ដែលអាមេរិកបានបើកដំណើរការស្ថានទូតមានទីតាំងស្ថិតក្នុងទីក្រុងភ្នំពេញ ដោយមានលោកDonald R. Heath ជាតំណាងវិសាមញ្ញនិងពេញសមត្ថភាពដំបូងរបស់អាមេរិកប្រចាំនៅក្នុងប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរ សាធារណរដ្ឋចិនបានបើកដំណើរការស្ថានទូតខ្លួនក្នុងទឹកដីប្រទេសកម្ពុជានៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៦ ដែលជាការស្ថាបនាឡើងនូវទំនាក់ទំនងការផ្លូវការ។ ក្រោយមកទំនាក់ទំនងការទូតរវាងកម្ពុជានិងរុស្ស៊ីក៏ចាប់ដំណើរការជាផ្លូវការផងដែរនាខែកក្កដា ឆ្នាំ១៩៥៨ ។ ក្រៅពីនេះ ប្រទេសកម្ពុជាក៏បានផ្សារភ្ជាប់ទំនាក់ទំនងការបរទេសជាមួយបណ្តាប្រទេសជាមិត្តរួមតំបន់ អាស៊ីអាគ្នេយ៍ អាស៊ីកណ្តាល ក៏ដូចជាបណ្តាប្រទេសនៅក្នុងទ្វីបអ៊ឺរ៉ុប និងទ្វីបអាមេរិកជាបន្តបន្ទាប់ថែមទៀតផង។ ទន្ទឹមនឹងមានការទទួលស្គាល់នូវអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត ប្រទេសកម្ពុជាបានចេញសេចក្តីថ្លែងការណ៍មួយភ្ជាប់ជាមួយនឹងសច្ចាប័ននេះថា កម្ពុជាបដិសេធមិនទទួលយកឬអនុវត្តតាមវាក្យខ័ណ្ឌទី២ នៃមាត្រា៣៧របស់អនុសញ្ញាឡើយ ហើយការខ្លឹមសារនេះធ្វើឡើងក្នុងឆ្នាំប្រហាក់ប្រហែលនឹងការទទួលស្គាល់អនុសញ្ញាដែរ។[1] កត្តានេះក៏ដោយសារប្រទេសកម្ពុជា មិនអាចទទួលយកបាននូវកាតព្វកិច្ចមានខ្លឹមសារថា ប្រទេសទាំងឡាយ ដែលជាភាគីនៃអនុសញ្ញាការទូតចាំបាច់ត្រូវផ្តល់អភ័យឯក

[1] សៀវភៅ ច្បាប់ការទូតរបស់បណ្ឌិត ស៊ា កុសលឆ្នាំ១៩៩៩ ទំព័រទី១៣

សិទ្ធិនិងបុព្វសិទ្ធិដល់ក្រុមបុគ្គលិករដ្ឋបាលនិងបច្ចេកទេស នៃស្ថានបេសកកម្មប្រចាំនៅក្នុងប្រទេសខ្លួន ដែលប្រហាក់ប្រហែលទៅនឹងអភ័យឯកសិទ្ធិនិងបុព្វសិទ្ធិរបស់អ្នកការទូតមែនទែនដែរ។[2] ទោះបីជាយ៉ាងនេះក្តី បច្ចុប្បន្នមិនមានលិខិតបទដ្ឋានគតិយុត្តិណាមួយអាចបញ្ជាក់ឱ្យបានច្បាស់លាស់ថា ប្រទេសកម្ពុជានៅបន្តមិនទទួលអនុវត្តវាក្យខ័ណ្ឌទី២ នៃមាត្រា៣៧នេះ ឬបានសម្រេចកែប្រែមកទទួលអនុវត្តឬយ៉ាងណានោះទេ។ ប៉ុន្តែចំណុច ដែលគួរកត់សម្គាល់គឺប្រទេសកម្ពុជាបានប្រើប្រាស់អនុសញ្ញានេះយ៉ាងទូលំទូលាយក្នុងប្រតិបត្តិការបរទេសជាមួយរដ្ឋជាច្រើន។ ពោលគឺក្នុងឆ្នាំ២០១៩ ទំនាក់ទំនងការបរទេសរបស់កម្ពុជាមានការរីកធំធាត់ដោយបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយ ១៧៤ ប្រទេសជុំវិញពិភពលោក ក្នុងនោះកម្ពុជាមានស្ថានតំណាងរបស់ខ្លួនប្រចាំនៅបរទេសចំនួន ៦៣និងបានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការជាមួយប្រទេសចំនួន ៣៤ ផងដែរ។[3]

## ២. ការស្ថាបនាទំនាក់ទំនងការទូត

នៅក្នុងឆាកអន្តរជាតិ ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ ជាកត្តាចម្បងសម្រាប់ជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចជាតិ ការអភិវឌ្ឍន៍សង្គម ភាពរីកសុះសាយនៃវប្បធម៌ អរិយធម៌ ប្រពៃណីទំនៀមទំលាប់តាមរបត់នៃសកលភាវូបនីយកម្ម ហេតុនេះហើយការផ្តើមទំនាក់ទំនងការបរទេសមានសារៈប្រយោជន៍ណាស់។ ក្នុងនោះផងដែរ បើយើងលើកយកបរិបថសង្គមមកធ្វើការប្រៀបធៀប ទំនាក់ទំនងរវាងបុគ្គលនិងបុគ្គលកសាងឡើងពីការព្រមព្រៀងដោយភាគីទាំងសងខាង ហើយស្របតាមការសិក្សាអក្សរសាស្ត្រខ្មែរពាក្យស្លោកមួយឃ្លាហាក់សមស្របជាមួយនឹងទិដ្ឋភាពនេះណាស់ គឺមានទៅមានមក អ្វីៗត្រូវមានទៅនិងមានមកទាំងទឹកចិត្ត ទាំងសម្ភារៈ ទាំងទំនាក់ទំនង។ ដូចគ្នាដែរចំពោះបរិបថអន្តរជាតិ រដ្ឋនីមួយៗ ដែលមានបំណងក្នុងការផ្តើមទំនាក់ទំនងការបរទេសជាមួយនឹងរដ្ឋដទៃទៀតចាំបាច់ត្រូវមានការព្រមព្រៀងអំពីសំណាក់ភាគីទាំងអស់ ដែលអាចជាទំនាក់ទំនងទ្វេភាគី ឬពហុភាគី។ ម្យ៉ាងវិញទៀត តាមច្បាប់អន្តរជាតិ រដ្ឋអធិបតេយ្យមានសមត្ថភាពគ្រប់គ្រាន់ដោយសេរី ដោយស្មើភាពនិងដោយទូលំទូលាយក្នុងការបង្កើតចំណងមិត្តភាពជាមួយគ្រប់បណ្តាប្រទេសនៅលើពិភពលោក។ ពោលគឺគ្មានបញ្ញត្តិណា ដែលកំណត់ឱ្យរដ្ឋណាមួយមានសិទ្ធិបង្ខិតបង្ខំ ឬកៀបសង្កត់ឱ្យរដ្ឋម្ខាងទៀតត្រូវតែធ្វើទំនាក់ទំនងការទូតជាមួយខ្លួន ឬបើកស្ថានទូតប្រចាំនៅក្នុងរាជធានីរបស់ខ្លួននោះឡើយ។ ទិដ្ឋភាពនេះ ជាកត្តាសំខាន់បំផុតក្នុងការកសាងប្រតិបត្តិការអន្តរជាតិ ហើយក៏ជាចំណុចសំខាន់នៅក្នុងអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតមាត្រា២ បានចែងថា ការបង្កើតទំនាក់ទំនងការទូតរវាងបណ្តារដ្ឋនិងការបង្កើតបេសកកម្មការទូតអចិន្ត្រៃយ៍ធ្វើឡើងដោយការយល់ព្រមគ្នាទៅវិញទៅមក។

[2] ដូចចំណុច[1]

[3] របាយការណ៍សង្ខេបរបស់ឯកឧត្តម អ៊ុច បូររិទ្ធ រដ្ឋមន្ត្រីប្រតិភូនិងជារដ្ឋលេខាប្រចាំការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិស្តីពីសមិទ្ធផលដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០១៩ ទំព័រទី៥

ក្នុងការអនុវត្តជាក់ស្តែង ប្រទេសនីមួយៗតែងរង់ចាំដល់មានឱកាសល្អ ដែលខ្លួនអាចទទួលបានផលប្រយោជន៍ពីកិច្ចសហការជាមួយប្រទេសម្ខាងទៀត ទើបសម្រេចបង្កើតទំនាក់ទំនងការទូតនោះជាផ្លូវការរវាងគ្នានិងគ្នា។ ជាការពិតណាស់ គោលនយោបាយការបរទេសបែបនេះតែងស្ថិតក្នុងគោលគំនិតរបស់រដ្ឋាភិបាលនៃរដ្ឋទាំងអស់ទៅហើយបើទោះបីជាពួកគេមិនបានបង្ហាញច្បាស់លាស់ក៏ដោយ។ ជាក់ស្តែង ទំនាក់ទំនងរវាងអ៊ីស្រាអែលនិងប្រជាមានិតចិនមានតាំងពីឆ្នាំ១៩៤៩ ប៉ុន្តែរំលងជាងជិតកន្លះសតវត្សរ៍ ទើបប្រទេសទាំងពីរសម្រេចបង្កើតទំនាក់ទំនងការទូតជាផ្លូវការជាមួយគ្នានៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩២។[4] ជាមួយគ្នានេះដែរ ទំនាក់ទំនងរវាងកម្ពុជានិងអាមេរិកក៏មិនចាប់ផ្តើមភ្លាមៗនោះឡើយ ពោលគឺ នៅចុងទសវត្សរ៍១៨០០ សហរដ្ឋអាមេរិកបានបង្កើតការិយាល័យកុងស៊ុលនៅប្រទេសវៀតណាមដែលជាប្រទេសជិតខាងរបស់កម្ពុជា ដោយសហរដ្ឋអាមេរិកមិនទាន់មានវត្តមានជាផ្លូវការនៅក្រុងភ្នំពេញឡើយ ទើបមានក្នុងឆ្នាំ១៩៥០ប៉ុណ្ណោះ។ ការទាក់ទងរវាងសហរដ្ឋអាមេរិកនិងប្រទេសកម្ពុជា នៅសតវត្សរ៍ទី១៩និងដើមសតវត្សរ៍ទី២០ ធ្វើឡើងតាមរយៈអ្នកដើរផ្សព្វផ្សាយសាសនា អ្នកផ្សងព្រេងនិងអ្នកជំនាញបែបវិទ្យាសាស្ត្រតែប៉ុណ្ណោះ។[5] ក្រោយមកអំឡុងទសវត្សរ៍១៩៧០ កម្ពុជានិងអាមេរិកពុំមានទំនាក់ទំនងការទូតល្អឡើយ ដោយសារកត្តាសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជានិងដោយសារការទម្លាក់គ្រាប់បែកពីសំណាក់អាមេរិកមកលើប្រជាជាតិខ្មែរ។[6] ដោយឡែក នៅអំឡុងសម័យសង្គ្រាមត្រជាក់ ទំនាក់ទំនងរវាងប្រទេសទាំងពីរមានការប្រែប្រួលគួរឱ្យកត់សម្គាល់ ដោយហេតុថាក្នុងពេលនោះ គោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក ផ្តោតច្រើនឡើងៗទៅលើការទប់ទល់នូវការរីករាលដាលនៃរបបកុម្មុយនិស្តក្នុងតំបន់អាស៊ីអាគ្នេយ៍ ទើបចំណងមិត្តភាពមួយនេះចាប់មានសារៈសំខាន់ជាថ្មី ចំពោះសហរដ្ឋអាមេរិក។[7]

ការបង្កើតទំនាក់ទំនងការទូត មិនចាំបាច់តែរដ្ឋនីមួយៗត្រូវបើកស្ថានទូតនៅក្នុងទឹកដីរបស់រដ្ឋម្ខាងទៀតឡើយ ហើយអ្នកការទូតទៀតសោត អាចត្រូវបានចាត់តាំងឱ្យតំណាងរដ្ឋសាមីនៅរដ្ឋដទៃពីរ ឬច្រើនក្នុងពេលតែមួយបាន តែទាមទារឱ្យមានការយល់ព្រមពីរដ្ឋទាំងអស់។ យោងតាមវាក្យខ័ណ្ឌទី១ ក្នុងមាត្រា៥ នៃអនុសញ្ញាទីក្រុងវៀនមានខ្លឹមសារថា រដ្ឋដាក់ទូតអាចដាក់ប្រមុខបេសកកម្ម ឬសមាជិកនៃបុគ្គលិកណាមួយទៅតាមករណីនីមួយៗឱ្យនៅអមបណ្តារដ្ឋជាច្រើនទៀត បើសិនជារដ្ឋម្ចាស់ផ្ទះណាមួយមិនបង្ហាញការជំទាស់ចំពោះបញ្ហានេះទេ។ ការចាត់ទូតបែបនេះ អាចជាករណីរដ្ឋដាក់ទូតមិនមានថវិការគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ស្ថានទូតច្រើន។ ជាឧទាហរណ៍ ដូចបានបកស្រាយខាងលើថាប្រទេសកម្ពុជាបានភ្ជាប់ទំនាក់ទំនងជាមួយ ១៧៤ ប្រទេសនៅជុំវិញ

[4] សៀវភៅ ច្បាប់ការទូត របស់បណ្ឌិត ស៊ា កុសលឆ្នាំ១៩៩៩ ទំព័រទី១៧

[5] សៀវភៅ ទំនាក់ទំងសហរដ្ឋអាមេរិកនិងកម្ពុជា(សម្រាប់ខួបលើកទី ៦០ នៃទំនាក់ទំនងការទូត អាមេរិកនិងកម្ពុជា ១៩៥០-២០១០)

[6] ដូចចំណុច[5]

[7] ដូចចំណុច[5]

ពិភពលោក តែកម្ពុជាមានស្ថានទូតរបស់ខ្លួនប្រចាំនៅបរទេសតែចំនួន ៦៣ ទីតាំងប៉ុណ្ណោះ។ នេះក៏ដោយសារកម្ពុជាមិនមានហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ស្ថានទូតនៅគ្រប់ ១៧៤ ប្រទេសឡើយ។ ក្រៅពីករណីដូចនេះ ក៏អាចមកពីភាពមិនស៊ីជម្រៅនៃទំនាក់ទំនងការទូតផងដែរ ពោលរដ្ឋទាំងសងខាងអាចមិនទាន់រកឃើញផលប្រយោជន៍ដែលខ្លួនអាចទទួលបានពីសំណាក់ភាគី ហេតុនេះហើយស្ថិតនៅជាទំនាក់ទំនងកម្រិតស្រាល។ ជាក់ស្តែងក្នុងឆ្នាំ២០១៩ កម្ពុជាបានផ្តើមទំនាក់ទំនងការទូតថ្មីមួយជាមួយប្រទេស បាបាដុស ដោយអ្នកតំណាងអចិន្ត្រៃយ៍របស់កម្ពុជានៅអង្គការសហប្រជាជាតិ ត្រូវតែងតាំងជាតំណាងសម្រាប់ប្រទេសបាបាដុសផងដែរ។[8]

### ២. ១. បេសកកម្មការទូត

ក្របខ័ណ្ឌអន្តរជាតិបានឱ្យនិយមន័យ ក្រុមបុគ្គលដែលតំណាងឱ្យរដ្ឋខ្លួនប្រចាំនៅរដ្ឋដទៃ ឬអង្គការអន្តរជាតិ ហើយបំពេញតួនាទីជាអ្នកទំនាក់ទំនងជាមួយនឹងបរទេសឬអង្គការអន្តរជាតិនោះ ថាជាប្រតិបត្តិការ **បេសកកម្មការទូត**។ តាមអនុសញ្ញាទីក្រុងវីយែន បេសកកម្មការទូតជាអចិន្ត្រៃយ៍ចាំបាច់ត្រូវមានការយល់ព្រមពីភាគីទាំងសងខាង។ រាល់ដំណើរការនៃបេសកកម្មនេះ ច្បាប់ការទូតកំណត់ឱ្យមានអ្នកតំណាងមួយរូបមានមុខងារហៅថា **ប្រមុខបេសកកម្ម**។ ទន្ទឹមនឹងនេះ ច្បាប់ការទូតបានបែងចែកប្រមុខបេសកកម្មជាបីប្រភេទទៅតាមទំហំ ឬលក្ខណៈនៃបេសកកម្មការទូត ហើយការបែងចែកដោយផ្អែកលើទំហំ ឬលក្ខណៈយ៉ាងណានឹងធ្វើការបកស្រាយលំអិតក្នុងចំណុច២. ៣. សមាជិកនៃបេសកកម្មការទូត (ក. ប្រមុខនៃបេសកកម្ម)។

ក្នុងការអនុវត្តជាក់ស្តែង បេសកកម្មការទូតត្រូវបានជំនួសដោយឃ្លា បេសកកម្មអចិន្ត្រៃយ៍ ហើយមានអត្ថន័យដូចគ្នាទៅនឹងទីស្ថានបេសកកម្មដែរ។ ឧទាហរណ៍ រដ្ឋមួយបានបំពេញបេសកកម្មអចិន្ត្រៃយ៍ក្នុងរដ្ឋម្ខាងទៀត មានន័យថារដ្ឋមួយនោះបានបើកដំណើរការស្ថានទូតក្នុងទឹកដីនៃរដ្ឋម្ខាងទៀត។ មិនតែប៉ុណ្ណោះ តាមមាត្រា១ ចំណុច ឈ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១ ទីស្ថានបេសកកម្ម គឺជាអាគារ ឬផ្នែកនៃអាគារ និងទីលានជាប់នឹងអាគារនោះទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ដែលប្រើប្រាស់ក្នុងផលប្រយោជន៍របស់បេសកកម្ម រួមទាំងលំនៅស្ថានរបស់ប្រមុខបេសកកម្មផងដែរ។ ការណ៍ដែលគេនិយមពាក្យស្ថានទូត (embassy) គឺជាពាក្យសាមញ្ញ ដែលគេប្រើសម្រាប់សម្គាល់ទីស្ថានបេសកកម្មក្នុងការប្រស្រ័យប្រចាំថ្ងៃ ដោយជាទូទៅមានទីតាំងស្ថិតនៅក្នុងរាជធានីនៃរដ្ឋម្ចាស់ផ្ទះ។ សរុបមកវិញ បេសកកម្មអចិន្ត្រៃយ៍ ជា

[8] គេហទំព័រ The Phnom Penh Post(ការសែតភ្នំពេញប៉ុស្តិ៍)ក្រោមចំណងជើង Cambodia and Barbados forge new diplomatic ties ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។ ចូលអានថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១។ តំណភ្ជាប់ https://m.phnompenhpost.com/national/cambodia-and-barbados-forge-new-diplomatic-ties?fbclid=IwAR0ZGuSrGpOEdtg5GAOWc4IwpNCvxXEv9_wlvWWU0GUGyfrSXwFqOYgnBhQ

ប្រតិបត្តិការដែលរដ្ឋដាក់ទូតបានបង្កើតស្ថានទូតនៅលើទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ ដែលមានលក្ខណៈយូរអង្វែង ហើយទំហំនៃប្រតិបត្តិការនេះមានភាពទូលំទូលាយ។ គួរជាទីកត់សម្គាល់ បេសកកម្មមួយបែបទៀតមានន័យជាភាសាអង់គ្លេសថា legation ខុសគ្នាពី ស្ថានទូត (embassy) ដែលបានបកស្រាយខាងលើ។ ពោល legation នេះជាស្ថានទូតទំហំតូចសម្រាប់ទំនាក់ទំនងការបរទេស ដែលមិនទាន់ស៊ីជម្រៅ ហើយអ្នកតំណាងម្នាក់ជាតំណាងប្រចាំរដ្ឋពីរ ឬច្រើនក្នុងពេលតែមួយ។

### ២. ២. មុខងារនៃបេសកកម្មការទូត

យោងតាមមាត្រា៣ នៃអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត មុខងារនៃបេសកកម្មការទូត មានដូចជា៖

#### ២. ២. ១. មុខងារតំណាង

មុខងារក្នុងការតំណាងឱ្យរដ្ឋដាក់ទូតប្រចាំនៅលើទឹកដីរបស់រដ្ឋម្ចាស់ផ្ទះនិងបំពេញតួនាទីពិភាក្សា ឬចរចារជាមួយរដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះ តាងនាមឱ្យរដ្ឋសាមីរបស់ខ្លួន។ លើសពីនេះ មុខងារតំណាង ចាំបាច់ក្នុងគោលបំណងជម្រុញទំនាក់ទំនងមិត្តភាព ក៏ដូចជាការអភិវឌ្ឍន៍ទំនាក់ទំនងលើវិស័យសេដ្ឋកិច្ច វប្បធម៌និងវិទ្យាសាស្ត្ររវាងប្រទេសទាំងពីរ។ ជាទូទៅ រាល់សកម្មភាពទំនាក់ទំនងរវាងរដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះ និងរដ្ឋាភិបាលនៃរដ្ឋដាក់ទូត ត្រូវធ្វើឡើងតាមរយៈស្ថានទូតរបស់រដ្ឋដាក់ទូត ដែលស្ថិតនៅក្នុងរដ្ឋម្ចាស់ផ្ទះផ្ទាល់។ នេះជាកត្តាសំខាន់ដែលគេសម្រេចបង្កើតស្ថានទូត ក៏ដោយសារគេយល់ឃើញអំពីភាពងាយស្រួល ឆាប់រហ័សនិងប្រសិទ្ធភាពក្នុងការធ្វើទំនាក់ទំនង។

#### ២. ២. ២. មុខងារការពារ

ចំពោះមុខងារការពារ គឺសំដៅការពារផលប្រយោជន៍របស់រដ្ឋដាក់ទូតនិងផលប្រយោជន៍ពលរដ្ឋរបស់ខ្លួនក្នុងទឹកដីរដ្ឋម្ចាស់ផ្ទះ ស្របតាមក្របខ័ណ្ឌដែលច្បាប់អន្តរជាតិបានអនុញ្ញាត។ ជារឿយៗ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េនិងថៃតែងអំពាវនាវឱ្យរដ្ឋទាំងពីរនេះយកចិត្តទុកដាក់លើកម្មករនិងពលកររបស់កម្ពុជាដែលបានទៅធ្វើការនិងស្នាក់នៅក្នុងទឹកដីនៃរដ្ឋទាំងពីរ។ នេះជាការបង្ហាញអំពីភាពយកចិត្តទុកដាក់របស់ស្ថានទូតកម្ពុជាប្រចាំនៅបរទេស ក្នុងការការពារផលប្រយោជន៍នានារបស់ពលរដ្ឋខ្លួន។

នៅលើសកលលោក ស្ថានទូតជាតិនិងអន្តរជាតិ តែងតែទទួលបានការណែនាំពីសំណាក់ក្រសួងការបរទេសរបស់គេឱ្យធ្វើការតវ៉ាចំពោះទង្វើរបស់រដ្ឋម្ចាស់ផ្ទះណាមួយ ដែលបានរំលោភបំពានមកលើពលរដ្ឋ ឬរដ្ឋរបស់គេ។ ដូចគ្នាដែរ រដ្ឋម្ចាស់ផ្ទះក៏អាចតវ៉ាទៅកាន់ទីស្ថានបេសកកម្មនៃរដ្ឋដាក់ទូតប្រចាំនៅរដ្ឋខ្លួន ចំពោះបញ្ហារំលោភបំពានមកលើខ្លួនពីសំណាក់រដ្ឋាភិបាលនៃរដ្ឋដាក់ទូត។ ជាក់ស្តែង កាលពីឆ្នាំ២០១៥ រដ្ឋាភិបាលកម្ពុជាបានដាក់កំណត់ឱ្យស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា ក៏ដូចជារដ្ឋាភិបាលរបស់គេបញ្ឈប់ជាបន្ទាន់នូវការជីកដី

ក្នុងគោលបំណងចាក់គ្រឹះសាងសង់ប៉ុស្តិ៍យោធាដោយខុសច្បាប់នៅក្នុងខេត្តកណ្តាល។[9] នេះជាទង្វើរំលោភបំពានដ៏ធ្ងន់ធ្ងរមួយមកលើដែនអធិបតេយ្យរបស់កម្ពុជា។ ស្របតាមច្បាប់អន្តរជាតិទាក់ទិនទៅនឹងដែនអធិបតេយ្យនៃរដ្ឋឯករាជ្យមួយ ភាគីកម្ពុជាមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងអនុវត្តនីតិវិធីរុះរើនិងចាប់ខ្លួនអ្នកដែលបើកដំណើរការសាងសង់នេះ ប៉ុន្តែភាគីកម្ពុជាជ្រើសរើសយកការដោះស្រាយដោយសន្តិវិធីដោយការដាក់កំណត់និងអំពាវនាវឱ្យបញ្ឈប់សកម្មភាពជាបន្ទាន់ ដែលនេះស្តែងឱ្យឃើញពីភាពថ្លៃថ្នូររបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនរវាងខ្លួននិងប្រទេសជិតខាង។

ក្រៅពីមុខងារតំណាងនិងការពារ បេសកកម្មការទូតមានមុខងារសំខាន់មួយទៀតគឺ មុខងារជាអ្នកប្រមូលផ្តុំព័ត៌មាននានា ហើយរាយការណ៍ព័ត៌មានទាំងនោះទៅកាន់រដ្ឋសាមី។

### ២. ២. ៣. មុខងារផ្តល់ព័ត៌មាន

ចុងក្រោយគឺមុខងារផ្តល់ព័ត៌មាន ភ្នាក់ងារការទូតត្រូវស្វែងយល់តាមគ្រប់មធ្យោបាយស្របច្បាប់ អំពីលក្ខខណ្ឌនិងការវិវត្តន៍នៃព្រឹត្តិការណ៍ក្នុងរដ្ឋម្ចាស់ផ្ទះ បន្ទាប់មកសរសេររបាយការណ៍អំពីរឿងនេះជូនរដ្ឋាភិបាលរបស់គេ។ នីតិវិធីទាំងមូល ត្រូវសមស្របទៅនឹងបញ្ញត្តិច្បាប់នៃរដ្ឋម្ចាស់ផ្ទះ ក៏ដូចជាបញ្ញត្តិនៃច្បាប់អន្តរជាតិផងដែរ។ មួយវិញទៀត បើទោះបីជាបញ្ញត្តិទាំងនោះ បានឬមិនបានកំណត់អំពីប្រធានបទនៃរបាយការណ៍ដែលគេគួរសរសេរក៏ដោយ ក៏របាយការណ៍ទាំងនោះត្រូវស្ថិតក្នុងកម្រិតមួយ ដែលមិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋម្ចាស់ផ្ទះ។ រដ្ឋដាក់ទូតអាចធ្វើការសម្រេចថា រដ្ឋខ្លួនចង់ស្វែងយល់ពីព្រឹត្តិការណ៍ ឬផ្នែកណាមួយ ដែលកើតឡើងក្នុងរដ្ឋម្ចាស់ផ្ទះ ហើយចាត់ចែងឱ្យអ្នកតំណាងរបស់ខ្លួនធ្វើការសិក្សាលើបញ្ហានោះ។ ជាក់ស្តែង ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា បានសរសេររបាយការណ៍ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស បញ្ហាសេដ្ឋកិច្ច បញ្ហាមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បញ្ហាភាវរកម្ម បញ្ហាជួញដូរមនុស្ស បញ្ហាសេរីភាពលើជំនឿសាសនានិងការអភិវឌ្ឍន៍សេរីភាពនិងប្រជាធិបតេយ្យជាអាទិ៍ ដែលកើតមានឡើងក្នុងប្រទេសកម្ពុជា ជារៀងរាល់ឆ្នាំ។[10]

## ២. ៣. សមាជិកនៃបេសកកម្មការទូត

យោងតាមចំណុច ខ ក្នុងមាត្រា១ នៃអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត សមាជិកនៃបេសកកម្ម គឺជាប្រមុខបេសកកម្មនិងសមាជិកនៃក្រុមបុគ្គលិករបស់បេសកកម្ម។ ក្នុងនោះ សមាជិកនៃបុគ្គលិករបស់បេសកកម្មមានដូចជា សមាជិកនៃក្រុមបុគ្គលិកមន្ត្រីការទូត ក្រុមបុគ្គលិករដ្ឋបាលនិងបច្ចេកទេសនិងក្រុម

[9] គេហទំព័រ អង្គការទិន្នន័យអំពីការអភិវឌ្ឍន៍ (Open Development Cambodia) ក្រោមចំណងជើង កម្ពុជាដាក់កំណត់ទូតមួយទៀតរឿងវៀតណាមសង់ប៉ុស្តិ៍យោធាចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៥។ ចូលអានថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១។ តំណភ្ជាប់ https://opendevelopmentcambodia.net/km/news/govt-again-challenges-vietnam-on-border/

[10] គេហទំព័រ U.S. Embassy in Cambodia (ស្ថានទូតសហរដ្ឋអាមេរិកនៅកម្ពុជា) ផ្នែក Official Reports។ ចូលអានថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១។ តំណភ្ជាប់ https://kh.usembassy.gov/our-relationship/official-reports/

បុគ្គលិកសេវាកម្ម។ លក្ខខណ្ឌគ្រឹះ ដើម្បីក្លាយខ្លួនជាសមាជិកណាម្នាក់នៃបេសកកម្មការទូត គេចាំបាច់ត្រូវមានសញ្ជាតិរបស់រដ្ឋដាក់ទូត ប៉ុន្តែក្នុងករណីខ្លះ ពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះក៏អាចមានសិទ្ធិក្លាយខ្លួនជាបុគ្គលិកស្ថានទូតអន្តរជាតិបានដែរ។ ចំពោះករណីនេះ នឹងធ្វើការសិក្សាលំអិតក្នុងចំណុចបន្ទាប់។

**២. ៣. ១. សញ្ជាតិ**

សមាជិកនៃបេសកកម្ម ចាំបាច់ត្រូវតែមានសញ្ជាតិរដ្ឋដាក់ទូត ឬអាចជាអ្នកដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះជាមុនសិន។ តាមមាត្រា៨ នៃអនុសញ្ញាបានកំណត់ដូចតទៅ៖

១. ជាគោលការណ៍ សមាជិកក្រុមបុគ្គលិកការទូតរបស់បេសកកម្មការទូត គួរមានសញ្ជាតិរដ្ឋដាក់ទូត។

២. សមាជិកក្រុមបុគ្គលិកការទូតរបស់បេសកកម្ម មិនគួរត្រូវតែងតាំងឡើងក្នុងចំណោមជនទាំងឡាយដែលមានសញ្ជាតិរដ្ឋម្ចាស់ផ្ទះឡើយ លើកលែងតែករណីមានការយល់ព្រមពីរដ្ឋនោះ ហើយការយល់ព្រមនោះទៀតសោត អាចដកវិញបានគ្រប់ពេលវេលា។

៣. រដ្ឋម្ចាស់ផ្ទះអាចរក្សាសិទ្ធិដដែលនេះ ចំពោះបណ្តាពលរដ្ឋរបស់រដ្ឋដទៃទៀត ដែលមិនមែនជាពលរដ្ឋរបស់រដ្ឋដាក់ទូត។

ក្រៅពីនេះ មានករណីលើកលែងចំពោះ ក្រុមបុគ្គលិករដ្ឋបាលនិងបច្ចេកទេសនិងក្រុមបុគ្គលិកសេវាកម្មចំពោះបញ្ហាសញ្ជាតិនេះផងដែរ។ សរុបមក សមាជិកនៃបេសកកម្ម អាចជាអ្នកដែលមានសញ្ជាតិនៃរដ្ឋដាក់ទូត ឬបុគ្គលដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះ ឬក៏បុគ្គលដែលមានសញ្ជាតិពីរ(សញ្ជាតិរបស់រដ្ឋដាក់ទូតផងនិងសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះផង) ក៏អាចក្លាយជាសមាជិកបេសកកម្មការទូតដែរ តែត្រូវមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះជាមុនសិន។ បើរដ្ឋដាក់ទូតសម្រេចទទួលយកបុគ្គលនោះជាសមាជិកបេសកកម្មរបស់គេ ទាំងការយល់ព្រមឱ្យបម្រើការ ទាំងការដកចេញពីក្រុម រដ្ឋម្ចាស់ផ្ទះជាអ្នកមានអាទិភាពធំបំផុតក្នុងការសម្រេចចិត្ត។ ការជ្រើសរើសពលរដ្ឋរបស់រដ្ឋម្ចាស់ផ្ទះមកបម្រើការក្នុងស្ថានទូតបរទេសភាគច្រើន គេជ្រើសរើសសម្រាប់មុខងារក្នុងក្រុមបុគ្គលិករដ្ឋបាលនិងបច្ចេកទេសនិងក្នុងក្រុមបុគ្គលិកសេវាកម្មដូចជា អ្នកសម្អាត អ្នកយាមនិងអ្នកលើកភេសជ្ជៈជាដើម ដោយសារការងារទាំងនេះមិនទាមទារបច្ចេកទេសខ្ពស់ ហេតុនេះគេមិនចាំបាច់ចំណាយថវិការយកពលរដ្ឋខ្លួនមករស់នៅបរទេសឡើយ។ ក្នុងករណីមួយផ្សេងទៀត សមាជិកបេសកកម្មមានសញ្ជាតិរបស់រដ្ឋទីបីពោលគេមិនមែនជាពលរដ្ឋនៃរដ្ឋដាក់ទូត ក៏មិនមែនជាពលរដ្ឋរបស់រដ្ឋម្ចាស់ផ្ទះដែរ។ ករណីបែបនេះ មានតិចតួចណាស់ ឬស្ទើរតែមិនមានសោះតែម្តង ប៉ុន្តែច្បាប់ការទូតមិនរឹតត្បិតនោះទេ និងបានបើកទូលាយសម្រាប់

លក្ខខណ្ឌនេះថែមទៀតផង។ គួររំលឹកផងដែរថា រដ្ឋម្ចាស់ផ្ទះមានសិទ្ធិទទួលយកនិងដកបុគ្គលនោះចេញពីស្ថានទូតបរទេសមានគ្រប់ពេលវេលាទាំងអស់។

បន្ទាប់ពីចំណុចលក្ខខណ្ឌសញ្ជាតិរបស់សមាជិកនៃបេសកកម្មនេះ ចំណុចបន្ទាប់នឹងធ្វើការសិក្សាទៅលើសមាជិកនីមួយៗនៃបេសកកម្មការទូត ក្នុងនោះមានប្រមុខនៃបេសកកម្មជាបុគ្គលសំខាន់បំផុតមកធ្វើការសិក្សាដំបូងគេ។

### ២. ៣. ២. ប្រមុខនៃបេសកកម្ម

ប្រមុខបេសកកម្ម គឺជាជន ដែលរដ្ឋាភិបាលដាក់ទូតចាត់តាំងឱ្យបម្រើសកម្មភាពក្នុងរដ្ឋម្ចាស់ផ្ទះក្នុងឋានៈនេះ។ ដូចបានបកស្រាយរួចមកហើយនៅចំណុចខាងលើ (២. ១.) ប្រមុខបេសកកម្មចែកចេញជា ៣ ថ្នាក់ដូចតទៅ៖[11]

- **ថ្នាក់ឯកអគ្គរាជទូត** (ambassador = ឯកអគ្គរដ្ឋទូត ឬអគ្គរាជទូត ឬអគ្គរដ្ឋទូត[12]) ឬអគ្គសមណៈទូត ជាប្រមុខបេសកកម្មថ្នាក់ខ្ពស់បំផុត អមប្រមុខរដ្ឋនិងប្រមុខបេសកកម្ម ផ្សេងដែលមានឋានៈស្មើគ្នា។ ថ្នាក់នេះ ប្រើសម្គាល់ប្រមុខបេសកកម្ម ដែលរដ្ឋសាមីបានបង្កើតស្ថានទូតផ្លូវការ (embassy) នៅរដ្ឋម្ចាស់ផ្ទះ។
- **ថ្នាក់ប្រេសិទ** (envoy) អគ្គរដ្ឋនិងសមណៈទូតរង ជាប្រមុខបេសកកម្មថ្នាក់ទី២ នៅអមប្រមុខរដ្ឋ។ ថ្នាក់នេះប្រើសម្គាល់ប្រមុខបេសកកម្ម ដែលជាទូទៅរដ្ឋសាមីមានទីស្ថានជា legation ដោយប្រមុខបេសកកម្មជាអ្នកតំណាងប្រចាំរដ្ឋពីរ ឬច្រើនក្នុងពេលតែមួយនិងមិនមានលំនៅស្ថានអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះឡើយ។
- **ថ្នាក់ភារៈធានី** (chargé d'affaires ឬchargé d'affaires en pied) ជាប្រមុខបេសកកម្មថ្នាក់ទី ៣ នៅអមរដ្ឋមន្ត្រីការបរទេស។

យ៉ាងណាមិញ ក្នុងការបំពេញភារកិច្ចតាងនាមឱ្យរដ្ឋសាមីចំពោះរដ្ឋដទៃ ប្រមុខបេសកកម្មទាំង ៣ ថ្នាក់នេះមិនមានភាពខុសប្លែកពីគ្នាឡើយ ពោលគឺពួកមានសមត្ថភាពពេលលេញនិងសិទ្ធិដូចៗគ្នា ហើយរាល់ការពិភាក្សានិងឯកសារ ដែលចេញដោយប្រមុខបេសកកម្មទាំង ៣ ថ្នាក់មានតម្លៃស្មើៗគ្នា។ ទោះជាយ៉ាងនោះក្តី រដ្ឋទាំងឡាយត្រូវព្រមព្រៀងគ្នាឱ្យបានច្បាស់លាស់អំពីថ្នាក់ ដែលប្រមុខបេសកកម្មរបស់ខ្លួនត្រូវទទួល។[13]

---

[11] អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា១៤

[12] សន្ទានុក្រមវិទ្យាសាស្ត្រនយោបាយនិងការទូត (ខ្មែរ-អង់គ្លេស-បារាំង) ឆ្នាំ២០១៤ លេខរៀងទី៨៦

[13] អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា១៥

នីតិវិធីក្នុងការតែងតាំងប្រមុខបេសកកម្មមានចែងយ៉ាងច្បាស់ ចាប់ពីមាត្រា៤ ដល់មាត្រា១៦ នៃអនុសញ្ញាទីក្រុងវ៉ៀន។ ជាសង្ខេប នីតិវិធីនេះ មានដូចតទៅ៖[14]

១. រដ្ឋដាក់ទូត ជ្រើសរើសបេសកជនជាប្រមុខបេសកកម្ម ហើយដាក់សំណើទៅកាន់រដ្ឋម្ចាស់ផ្ទះ

២. រដ្ឋម្ចាស់ផ្ទះ ផ្តល់ឱ្យការយល់ព្រម ដល់បុគ្គលនោះ។ បើរដ្ឋម្ចាស់ផ្ទះមិនពេញចិត្តបុគ្គលនោះទេ គេមានសិទ្ធិបដិសេធដោយមិនចាំបាច់ប្រាប់ហេតុផល។ រីឯ រដ្ឋដាក់ទូតត្រូវជ្រើសរើសបេក្ខជនដាក់ស្នើជាថ្មី រហូតមានការយល់ព្រមជាស្ថាពរ

៣. រដ្ឋដាក់ទូត ចេញសារតាំងឱ្យប្រមុខបេសកកម្មនោះ

៤. ជាចុងក្រោយរដ្ឋម្ចាស់ផ្ទះប្រារព្ធពិធីទទួលសារតាំង ដើម្បីទទួលប្រមុខបេសកកម្មបរទេសមកប្រចាំនៅប្រទេសខ្លួន។

ក្រៅពីប្រមុខបេសកកម្ម ក្រុមដែលចូលរួមយ៉ាងសកម្មក្នុងបេសកកម្មការទូត គឺសមាជិកនៃក្រុមបុគ្គលិកមន្ត្រីការទូតនេះឯង។ សូមបញ្ជាក់ផងដែរថា ប្រមុខបេសកកម្មម្នាក់ ស្ថិតក្នុងថ្នាក់ណាមួយនៃថ្នាក់ទាំងបីខាងលើ ជាបុគ្គលដែលមានឋានន្តរសក្តិខ្ពស់បំផុតក្នុងចំណោមសមាជិកមន្ត្រីការទូតទាំងអស់ចាត់តាំងឱ្យបម្រើការក្នុងរដ្ឋណាមួយ។

### ២. ៣. ៣. សមាជិកនៃក្រុមបុគ្គលិកមន្ត្រីការទូត

សមាជិកនៃក្រុមបុគ្គលិកមន្ត្រីការទូត សំដៅទៅលើសមាជិកនៃបេសកកម្ម ដែលមានឋានន្តរសក្តិ ឬអាសនានុក្រមជាមន្ត្រីការទូត មានដូចជា៖[15]

- **ឯកអគ្គរាជទូត** ជាឋានន្តរសក្តិខ្ពស់បំផុតក្នុងស្ថានទូត មានសិទ្ធិអំណាចដូចជា រដ្ឋមន្ត្រីនៃក្រសួងមួយ។ ក្រោមឯកអគ្គរាជទូត មានភារៈធានីស្តីទី (chargé d'affaires ad interim) ដែលទទួលបន្ទុកជំនួសឯកអគ្គរាជទូត ក្នុងរយៈពេលមួយកំណត់។ ភារៈធានីស្តីទីនេះ មិនមែនជាឋានន្តរសក្តិផ្លូវការឡើយ ពួកគេគ្រាន់តែជាអ្នកជំនួសបណ្តោះអាសន្ន ពេលឯកអគ្គរាជទូតអវត្តមាន។ ឯកអគ្គរាជទូត អាចជ្រើសរើសអគ្គទីប្រឹក្សា ទីប្រឹក្សា ឬលេខាធិការ ជាភារៈធានីស្តីទីតំណាងខ្លួនបាន។
- **អគ្គទីប្រឹក្សា**(Minister-counsellor)
- **ទីប្រឹក្សា**(Counsellor)
- **លេខាធិកាទី ១** (First secretary)

---

[14] សៀវភៅ ច្បាប់ការទូតរបស់បណ្ឌិត ស៊ា កុសល ឆ្នាំ១៩៩៩ ទំព័រទី៣២

[15] គេហទំព័រ Debrett's (London 1769) ផ្នែក The Diplomatic Service ចូលអានថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១។ តំណភ្ជាប់ https://www.debretts.com/expertise/forms-of-address/professions/the-diplomatic-service/

- **លេខាធិកាទី ២**(Second secretary)
- **លេខាធិកាទី ៣**(Third secretary)
- **អនុព័ន្ធ**(Attaché)
- **ជំនួយការអនុព័ន្ធ**(Assistant attaché)។

ឋានន្តរសក្តិនេះ មិនសុទ្ធតែមាននៅក្នុងស្ថានទូតឡើយ ដោយប្រែប្រួលទៅតាមការសម្រេចចិត្តនិងទំហំសកម្មភាពបេសកកម្មរបស់រដ្ឋដាក់ទូត។ ចំពោះបេសកកម្មមានទំហំតូច ឋានៈមួយចំនួនត្រូវបានលុបបំបាត់។ម្យ៉ាងវិញទៀត ចំពោះអនុព័ន្ធនិងជំនួយការអនុព័ន្ធប្រើសម្រាប់ភ្នាក់ងារការទូតនានា ដែលមិនមានសមត្ថភាពពេញលេញអាចទទួលឋានន្តរសក្តិថ្នាក់លេខាឡើងទៅ ហើយជាទូទៅពួកគេបម្រើការក្នុងតួនាទីចាំបាច់ណាមួយដែលបេសកកម្មតម្រូវ។ អនុព័ន្ធនិងជំនួយការអនុព័ន្ធ ក៏អាចជាសមាជិកនៃមន្ត្រីយោធា ជើងទឹកនិងជើងអាកាសផងដែរ។[16]

រដ្ឋដាក់ទូត អាចតែងតាំងមន្ត្រីការទូតក្រៅពីថ្នាក់ប្រមុខបេសកកម្មបានដោយសេរីនិងមានកាតព្វកិច្ចត្រឹមជូនជាព័ត៌មានប៉ុណ្ណោះ ហើយការជូនដំណឹងនេះទៀតសោត ជាបន្ទុករបស់ប្រមុខបេសកកម្ម ដោយធ្វើឡើងជាលាយលក្ខណ៍អក្សរអំពីលំដាប់អាសនានុក្រមរបស់សមាជិកទាំងឡាយ។ តែរដ្ឋម្ចាស់ផ្ទះ អាចមានសិទ្ធិធ្វើការបដិសេធមិនទទួលមន្ត្រីប្រភេទណាមួយដោយឈរលើមូលដ្ឋានដូចគ្នានិងដោយគ្មានការរើសអើង។[17]

សមាជិកបេសកកម្មពីរក្រុមចុងក្រោយគឺ សមាជិកក្រុមរដ្ឋបាលបច្ចេកទេសនិងក្រុមបុគ្គលិកសេវាកម្ម។

### ២. ៣. ៤. សមាជិកនៃក្រុមរដ្ឋបាលនិងបច្ចេកទេស

សមាជិកនៃក្រុមរដ្ឋបាលនិងបច្ចេកទេស គឺជាសមាជិកបេសកកម្ម ដែលបម្រើការងាររដ្ឋបាល ឬបច្ចេកទេសនៅក្នុងបេសកកម្មការទូតនោះ ដូចជាអ្នករត់សំបុត្រ បុគ្គលិកគណនេយ្យ អ្នកវាយកុំព្យូទ័រ ជាងភ្លើងជាដើម។ សមាជិកនៃក្រុមរដ្ឋបាលនិងបច្ចេកទេស ជួនកាលជាអ្នកដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះ។

ដោយសារភាពចាំបាច់ប្រមុខបេសកកម្ម ឬមន្ត្រីការទូត អាចទទួលអ្នកមានសញ្ជាតិរដ្ឋម្ចាស់ផ្ទះមកធ្វើការនៅក្នុងស្ថានទូតរបស់គេបានផងដែរ។

### ២. ៣. ៥. សមាជិកនៃក្រុមបុគ្គលិកសេវាកម្ម

សមាជិកនៃក្រុមបុគ្គលិកសេវាកម្ម ជាសមាជិកបេសកកម្ម ដែលមានមុខងារជាអ្នកផ្តល់សេវាកម្មផ្សេងៗដែលជាសេចក្តីចាំបាច់បេសកកម្មការទូតនោះ រួមមាន អ្នកយាមកាមសម្រាប់ស្ថានទូត ឬលំនៅស្ថានរបស់

[16] អនុសញ្ញាទីក្រុងវីយ៉េនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៧

[17] អនុសញ្ញាទីក្រុងវីយ៉េនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា១១ វាក្យខ័ណ្ឌទី២

ភ្នាក់ងារការទូត ឬអ្នកបម្រើភេសជ្ជៈ។ សមាជិកនៃក្រុមបុគ្គលិកសេវាកម្មផងដែរ ក៏អាចជា អ្នកដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះ។

ការកំណត់ឱ្យបានច្បាស់លាស់នូវឋានៈនិងតួនាទីនៃសមាជិកបេសកកម្មទាំងអស់នេះ ជាភាពចាំបាច់នៅក្នុងការសិក្សាស្វែងយល់អំពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិការទូតនៅក្នុងជំពូកទី ២និងទី៣ជាបន្តបន្ទាប់។

## ៣. ការបញ្ចប់ទំនាក់ទំនងការទូត

ក្នុងច្បាប់អន្តរជាតិ ការផ្តាច់ទំនាក់ទំនងការទូតហាក់មានភាពងាយស្រួលជាងការស្ថាបនា ដោយហេតុថា ប្រទេសទាំងពីរអាចកាត់ផ្តាច់ទំនាកទំនងការបរទេសរវាងគ្នានឹងគ្នាបាននៅគ្រប់ពេលវេលា។ ក្នុងការអនុវត្តជាក់ស្តែង ការហៅបេសកកម្មការទូតឱ្យចូលក្នុងប្រទេសជាតំណាងឱ្យការកាត់ផ្តាច់ទំនាក់ទំនងការទូត ជាស្ថាពរ ឬមួយរយៈពេលក្តី ដោយសារបញ្ហាសង្គ្រាមរ៉ាំរ៉ៃឬជម្លោះនយោបាយជាដើម។ ជាក់ស្តែងប្រទេសអាហ្វហ្កានីស្ថាន និងប៉ាគីស្ថានមានជម្លោះឥតស្រាក់ស្រាំដោយសារបញ្ហាព្រំដែននៃរដ្ឋទាំងពីរ ត្រង់ចំណុចឌូរ៉េដ (Durand Line) ដែលភាគីខាងអាហ្វហ្កានីស្ថានមិនទទួលស្គាល់ព្រំប្រទល់នេះឡើយ។ លើសពីនេះ ព្រឹត្តិការណ៍ថ្មីៗរវាងប្រទេសទាំងពីរក៏តែងតែកើតមានឡើងដូចជាអាហ្វហ្កានីស្ថានមានចោទប្រកាន់ថា ប៉ាគីស្ថាននៅពីក្រោយការប៉ុនប៉ងចាប់ជំរិតកូនស្រីរបស់ប្រធានាធិបតេយ្យអាហ្វហ្កានីស្ថាន ដែលជាកត្តាជម្រុញឱ្យប្រធានាធិបតេយ្យប្រទេសនេះសម្រេចហៅបេសកកម្មការទូតរបស់គេត្រឡប់ចូលក្នុងប្រទេសវិញ ចំណែកឯភាគីប៉ាគីស្ថានក៏បានហៅបេសកកម្មការទូតរបស់គេឱ្យត្រឡប់ចូលក្នុងប្រទេសវិញដូចគ្នា។ ការសម្រេចហៅអ្នកការទូតឱ្យវិលទៅកាន់ប្រទេសសាមីវិញ ជាសញ្ញាមិនល្អចំពោះទំនាក់ទំនងទ្វេភាគីដ៏ទន់ខ្សោយរវាងប្រទេសទាំងពីរនេះឡើយ។

ថ្វីបើរដ្ឋទាំងសងខាងជួបប្រទះនូវបញ្ហាបែបនេះ រដ្ឋនីមួយៗមានតួនាទីថែរក្សា ការពារ និងគោរពទីស្ថានបេសកកម្ម ទ្រព្យសម្បត្តិ ក៏ដូចជាសម្ភារៈនានានៃទីស្ថាននោះជានិច្ច ទោះបីក្នុងពេលខាងមុខប្រទេសទាំងពីរអាចឈានដល់មានជម្លោះផ្នែកយោធាក៏ដោយ។[18]

ជាទិសដៅក្នុងការសិក្សាតទៅនេះ យើងសម្រេចធ្វើការបែងចែងសិទ្ធិការទូតពិសេសជា ២ ជំពូកដាច់ដោយឡែកពីគ្នា គឺបុព្វសិទ្ធិការទូតនិងអភ័យឯកសិទ្ធិការទូត។បើទោះបីជា សិទ្ធិទាំងពីរបែបនេះមានភាពលំបាកនៅក្នុងការបែងចែក ប៉ុន្តែក៏មិនមានន័យថា គេមិនអាចបែងចែកបាននោះដែរ។ ហេតុនេះហើយ យើងនឹងទាញយកនូវចំណុច ខុសគ្នាគួរឱ្យកត់សម្គាល់មួយមកធ្វើជាគំនូរព្រំដែន។ ជាកិច្ចចាប់ផ្តើមក្នុងការសិក្សាជំពូកបន្តបន្ទាប់ អ្នកអានគួប្បីត្រូវចង់ចាំថា ការសម្រេចចិត្តក្នុងការបែងចែងរបស់ក្រុមយើងខ្ញុំ ដោយសំអាងថា បុព្វសិទ្ធិជាសិទ្ធិដែលតួអង្គអន្តរជាតិក៏ដូចជារដ្ឋម្ចាស់ផ្ទះបានបង្កើតឡើងថ្មីឬមានស្រាប់ក្នុងច្បាប់ ហើយត្រូវ

[18] អនុសញ្ញាទីក្រុងវ៉្យែនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៤៥

ធានាបន្ថែមអំពីប្រសិទ្ធភាពរបស់វា សម្រាប់ដំណើរការរលូននៃបេសកកម្មការទូតទាំងមូល។ ចំណែកឯអភ័យឯកសិទ្ធិជាសិទ្ធិ ដែលមានស្រាប់ក្នុងឋានានុក្រមនៃនីតិដែរ តែត្រូវបានតួអង្គនៃច្បាប់អន្តរជាតិនិងរដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះកំណត់លុបចោល ឬសម្រេចថាគ្មានអនុភាពចំពោះបេសកកម្មការទូតទាំងមូល។

# ជំពូកទី ២
# បុព្វសិទ្ធិការឆ្នោត

# ជំពូកទី ២
# បុព្វសិទ្ធិការទូត

## ១. និយមន័យ

បុព្វសិទ្ធិការទូត (diplomatic privileges) សំដៅទៅលើសិទ្ធិទាំងឡាយជាចម្បងជាអាទិភាព ដែលរដ្ឋម្ចាស់ផ្ទះផ្តល់ជូនសកម្មភាពការងាររបស់បេសកកម្មការទូត ដើម្បីដោះស្រាយបំបាត់ភាពសាំញ៉ាំរដ្ឋបាលទូទៅនៅក្នុងរដ្ឋម្ចាស់ផ្ទះ ដូចជាការលើកលែងការបង់ពន្ធដីរបស់ស្ថានទូត ពន្ធលើបៀវត្សរ៍របស់បុគ្គលិកស្ថានទូត ការនាំចូលសម្ភារៈនិងយានជំនិះសម្រាប់ស្ថានបេសកកម្មនិងបុគ្គលិកផ្ទាល់ ដោយការបង់ពន្ធនោះជាបន្ទុករបស់រដ្ឋម្ចាស់ផ្ទះ។

ដើម្បីជាភាពងាយស្រួលក្នុងការសិក្សា យើងបានធ្វើការកំណត់បុព្វសិទ្ធិការទូតជា ៣ ផ្នែកគឺបុព្វសិទ្ធិទាក់ទងនឹងទីស្ថានបេសកកម្ម បុព្វសិទ្ធិទាក់ទងនឹងដំណើរការបេសកកម្មនិងចុងក្រោយគឺបុព្វសិទ្ធិសម្រាប់សមាជិកបេសកកម្មផ្ទាល់។

## ២. ចំពោះទីស្ថាននៃបេសកកម្ម ( The premises of the mission)

ដូចដែលបានសិក្សាមកហើយ ទីស្ថានបេសកកម្ម ឬស្ថានទូត ជាទីកន្លែង ដែលរដ្ឋដាក់ទូតបង្កើតឡើងសម្រាប់ប្រតិបត្តិការទំនាក់ទំនងការទូតក្នុងដែនដីរដ្ឋម្ចាស់ផ្ទះ។ ក្នុងន័យនេះ ទីស្ថានបេសកកម្មសំដៅដល់ ស្ថានទូត គ្រឿងសង្ហារឹម វត្ថុផ្សេងៗនិងមធ្យោបាយធ្វើដំណើរ ដែលជាកម្មសិទ្ធិរបស់រដ្ឋដាក់ទូត។ បុព្វសិទ្ធិដំបូងនៃរដ្ឋដាក់ទូត គឺគេមានសិទ្ធិដាក់ទង់ជាតិនិងសញ្ញាសម្គាល់ជាតិរបស់គេ ទល់មុខទីស្ថានបេសកកម្មនិងលំនៅស្ថានរបស់ប្រមុខបេសកកម្មបានដោយសេរី។[19] លើសពីនេះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចសំខាន់ៗត្រូវផ្តល់ឱ្យទីស្ថានបេសកកម្មនេះ ដូចតទៅ៖

### ២. ១. ការជួយសម្រួល

រដ្ឋម្ចាស់ផ្ទះ មានតួនាទីចាំបាច់ណាស់ក្នុងការជួយសម្រួលនិងស្វែងរកទីតាំងក្នុងទឹកដីខ្លួនឱ្យដល់រដ្ឋដាក់ទូតក្នុងការស្ថាបនាស្ថានទូតរបស់គេ។ ស្របតាមវាក្យខ័ណ្ឌទី១ នៃមាត្រា២១ របស់អនុសញ្ញាទីក្រុងវ៉ៀនស្តីពីទំនាក់ទំនងការទូតបានចែងថា ស្របតាមច្បាប់របស់ខ្លួន រដ្ឋម្ចាស់ផ្ទះត្រូវសម្រួលដល់រដ្ឋដាក់ទូតនូវទីស្ថានចាំបាច់សម្រាប់បេសកកម្មក្នុងការទិញលំនៅស្ថាន ឬជួយបេសកកម្ម ស្វែងរកលំនៅស្ថានតាមមធ្យោបាយសមរម្យសម្រាប់សមាជិករបស់គេ។

### ២. ២. ភាពមិនអាចចំពារចំពានបាន

[19] អនុសញ្ញាទីក្រុងវ៉ៀនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា២០

ជាការពិតណាស់ ស្ថានទូតចាំបាច់ត្រូវទទួលបានការការពារជានិច្ចពីសំណាក់រដ្ឋម្ចាស់ផ្ទះ ដោយមិនអាចឱ្យបុគ្គល ទាំងរូបវន្តបុគ្គលនិងនីតិបុគ្គលណាមួយមកបំពារបំពាន ចូលដោយខុសច្បាប់ ឬបំផ្លាញទីស្ថាន ឬសម្ភារៈនៃទីស្ថានបានឡើយ។ រដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះ មិនមានសិទ្ធិចេញចូលដោយសេរីចំពោះផ្នែកណាមួយនៃស្ថានទូត ឬទីកន្លែងដែលបានប្រើប្រាស់ដាច់មុខសម្រាប់សេចក្ដីត្រូវការរបស់បេសកកម្មឡើយ។ ពោលគឺចាំបាច់ត្រូវមានការអនុញ្ញាតឱ្យចូលពីសំណាក់ប្រមុខបេសកកម្មតែមួយគត់។ បញ្ញត្តិនេះ យោងតាមវាក្យខ័ណ្ឌទី១និងទី២ នៃមាត្រា២២ របស់អនុសញ្ញាទីក្រុងវ៉ៀនស្ដីពីទំនាក់ទំនងការទូតៈ

១. ទីស្ថានបេសកកម្ម មិនអាចត្រូវបានបំពានឡើយ។ បណ្ដាភ្នាក់ងាររបស់រដ្ឋម្ចាស់ផ្ទះ មិនអាចចូលទៅក្នុងទីស្ថានបេសកកម្មនោះ ដោយគ្មានការយល់ព្រមពីប្រមុខបេសកកម្មបានឡើយ។

២. រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចពិសេស ក្នុងការចាត់គ្រប់វិធានការសមស្រប ដើម្បីទប់ស្កាត់មិនឱ្យទីស្ថានបេសកកម្មត្រូវបំពារបំពានឬត្រូវខូចខាត ហើយត្រូវរារាំងការរំខានដល់ភាពស្ងប់ស្ងាត់របស់ទីស្ថានបេសកកម្ម ឬភាពថ្លៃថ្នូររបស់ទីស្ថានបេសកកម្ម។

ក្នុងករណី ដែលមានអ្នកមកបំពានទីស្ថាននោះ រដ្ឋម្ចាស់ផ្ទះ ជាតួអង្គដែលត្រូវចាត់វិធានការតាមផ្លូវច្បាប់ចំពោះបុគ្គលនោះ ឬផ្ដល់ព្យសនកម្មសម្រាប់ការខូតខាតរបស់រដ្ឋដាក់ទូត។

ជាឧទាហរណ៍ កាលពីជាងពីរទសវត្សរ៍មុនចន្លោះឆ្នាំ២០០១និង ២០០៣ មានព្រឹត្តិការណ៍យ៉ាងសម្បោមមួយបានកើតឡើង ដោយពលរដ្ឋនិងសិស្សនិស្សិតកម្ពុជាបានធ្វើបាតុកម្មនិងដុតស្ថានទូតថៃប្រចាំនៅក្នុងប្រទេសកម្ពុជា។ កំហឹងនេះផ្ទុះឡើងដោយសារសម្ដីរបស់តារាស្រីថៃមួយរូប ដែលបានអះអាងថា ប្រាសាទអង្គរវត្តជារបស់ថៃនិងទាមទារឱ្យកម្ពុជាប្រគល់ប្រាសាទអង្គរវត្តទៅឱ្យជាតិសាសន៍គេវិញ។ ខណៈពេលនោះ មានសារព័ត៌មានកម្ពុជានិងថៃជាច្រើនបានចុះផ្សាយពាក្យពេចន៍ទាំងនេះនៅពាសពេញផ្ទៃប្រទេស។ ក្រោយមកប្រជាពលរដ្ឋនិងនិស្សិតកម្ពុជាជាច្រើនរយនាក់ បានចាប់ផ្ដើមបើកការតវ៉ាទាមទារឱ្យតារាស្រីថៃរូបនោះ ក៏ដូចជាភាគីថៃចេញមុខមកសុំទោសជាសាធារណៈ ប៉ុន្តែគេពុំឃើញមានការឆ្លើយពីសំណាក់ភាគីថៃណាម្នាក់នោះទេ ផ្ទុយទៅវិញ ក្រុមប៉ូលីសដែលយាមការក្នុងស្ថានទូតថៃ បានប្រើប្រាស់កាំភ្លើងបាញ់គំរាមក្រុមបាតុករជាច្រើនគ្រាប់ ជាកត្តាធ្វើឱ្យក្រុមនិស្សិតនិងពលរដ្ឋកាន់តែខឹងសម្បារ ដែលឈានដល់ការដុតស្ថានទូតថៃតែម្ដង។ ជុំវិញបញ្ហានេះ សេដ្ឋកិច្ចរបស់ប្រទេសថៃបានបាត់បង់ទឹកប្រាក់សរុបរហូតដល់ ៥៦ លានដុល្លារអាមេរិក រួមមកពីការដុតបំផ្លាញស្ថានទូតនិងវិធានការបិទច្រកព្រំដែនរវាងកម្ពុជានិងថៃអស់រយៈពេល៣ខែ ក៏ដូចជាបំរាមបិទការផ្សាយរឿងភាគថៃក្នុងប្រទេសកម្ពុជាអស់រយៈកាល១០ឆ្នាំផងដែរ។ ប៉ុន្តែរដ្ឋាភិបាលកម្ពុជាផ្ដល់សំណងជាទឹកប្រាក់ចំនួន ៦ លានដុល្លារអាមេរិកប៉ុណ្ណោះ ដែលព្យសនកម្មនេះផ្ដល់ឱ្យសម្រាប់ការខាតបង់ដែលពលរដ្ឋកម្ពុជាបានដុតបំផ្លាញស្ថានទូតថៃ។ ព្រឹត្តិការណ៍នេះ សបញ្ជាក់ឱ្យឃើញថា ទោះបីមានបញ្ហាណាមួយកើតឡើងក៏

ដោយរដ្ឋម្ចាស់ផ្ទះត្រូវបំពេញតួនាទីការពារផលប្រយោជន៍របស់ស្ថានទូតជានិច្ច។ ប្រសិនបើគេបរាជ័យក្នុងការការពារវិញនោះ រដ្ឋម្ចាស់ផ្ទះត្រូវទទួលរ៉ាប់រងរាល់ការខូតខាតទាំងឡាយដែលកើតមានចំពោះស្ថានទូត។

ស្ថានទូតមានសារៈសំខាន់ណាស់ចំពោះរដ្ឋដាក់ទូត តែដំណើរប្រព្រឹត្តទៅរបស់បេសកកម្មរឹតមានសារៈសំខាន់ទ្វេដង។ នៅចំណុចបន្ទាប់ យើងនឹងសិក្សាអំពីបុព្វសិទ្ធិ ដែលរដ្ឋម្ចាស់ផ្ទះគួរប្បីត្រូវបំពេញសម្រាប់ធានាដល់ភាពងាយស្រួលនៃដំណើរការបេសកកម្ម។

**៣. ចំពោះដំណើរការនៃបេសកកម្ម** ( The work of the mission )

ចំពោះដំណើរការនៃបេសកកម្ម គឺសំដៅទៅលើប្រតិបត្តិការទាំងឡាយដែលធ្វើឡើងក្នុងទិសដៅសម្រេចបេសកកម្មការទូត ដោយរួមបញ្ចូល ការងារតំណាង សម្របសម្រួល ការពារផលប្រយោជន៍រដ្ឋទាំងពីរនិងការងារផ្តល់ព័ត៌មានទៅកាន់រដ្ឋដាក់ទូតជាដើម។ នៅក្នុងប្រតិបត្តិការទាំងអស់នោះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចសំខាន់ៗដូចតទៅ៖

**៣. ១. ការជួយសម្រួល**

ជាធម្មតា ការទូតតែងត្រូវការជំនួយផ្សេងៗសម្រាប់អនុវត្តមុខងាររបស់គេឱ្យបានរលូន។ យោងតាមមាត្រា២៥ នៃអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត រដ្ឋម្ចាស់ផ្ទះត្រូវផ្តល់គ្រប់ភាពងាយស្រួល ដល់ការបំពេញមុខងាររបស់បេសកកម្មការទូត។ ដោយហេតុនេះថាប្រតិបត្តិធ្វើឡើងក្នុងទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ដូច្នោះជំនួយទាំងឡាយជាបន្ទុករបស់រដ្ឋម្ចាស់ផ្ទះ។ រដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះជាអ្នកមានកាតព្វកិច្ចផ្តល់ឱ្យដោយឥតលក្ខខណ្ឌ ហើយត្រូវធានានិងប្រើប្រាស់គ្រប់មធ្យោបាយដែលគេអាចធ្វើទៅបាន ដើម្បីបំពេញតម្រូវការទាំងអស់នោះ។ មួយវិញទៀតចំពោះទំហំ ឬប្រភេទការងារបែបណាដែលរដ្ឋម្ចាស់ផ្ទះត្រូវជួយសម្រួលនោះ អនុសញ្ញាមិនមានកំណត់ឱ្យបានច្បាស់លាស់នោះទេ។ ដូចនេះបានសេចក្តីថា រដ្ឋម្ចាស់ផ្ទះត្រូវជួយរាល់កិច្ចការទាំងឡាយណាដែលរដ្ឋដាក់ទូតថាជាដំណើរការនៃបេសកកម្ម។

**៣. ២. ភាពមិនអាចបំពារបំពានបាន**

មិនចំពោះតែប្រតិបត្តិការប៉ុណ្ណោះទេ នៅក្នុងទំនាក់ទំនងការទូត សម្ភារៈ ឯកសារ ឬទូរសារ សុទ្ធសឹងតែមានសារៈសំខាន់ហើយចាំបាច់ត្រូវមានការការពារជានិច្ច ពីព្រោះឯកសារទាំងអស់នោះចាត់ទុកជាកិច្ចការផ្ទៃក្នុងរបស់រដ្ឋមួយ។ ច្បាប់អន្តរជាតិ បានកំណត់ថារដ្ឋអធិបតេយ្យមួយមិនអាចឈ្លានពានកិច្ចការផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យដទៃឡើយ។ ហេតុនេះ វាជាកត្តាសំខាន់មួយដែលរដ្ឋម្ចាស់ផ្ទះគួរកត់ចំណាំជានិច្ចជាកាលរាល់កិច្ចការដែលពាក់ព័ន្ធនឹងស្ថានទូត។ ដោយយោងទៅតាមមាត្រា២៤ នៃអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត សារដ្ឋាននិងឯកសាររបស់បេសកកម្មមិនអាចត្រូវបានបំពានបានឡើយនៅគ្រប់ពេលនិងគ្រប់ទីកន្លែងដែលឯកសារទាំងនោះតាំងនៅ។ ពោលរដ្ឋម្ចាស់ផ្ទះ មិនអាចរំលោភបំពានសិទ្ធិ មិនអាចសុំពិនិត្យមើល ឬបើកមើលនូវ

រាល់ឯកសារជាក្រដាសក្តី ជាសារដ្ឋានក្តី ទោះបីជាឯកសារទាំងនោះស្ថិតនៅកន្លែងណាក៏ដោយ គ្រប់ពេលវេលា គេមិនអាចបើកឯកសារនោះបានដែរ។

មួយវិញទៀត រាល់ការទំនាក់ទំនងតាមទូរសារក្តី ឬតាមមធ្យោបាយផ្សេងៗទៀតក្តី បេសកកម្មការទូតមាន បុព្វសិទ្ធិគ្រប់គ្រាន់និងពេញលេញ ក្នុងការប្រស្រ័យទាក់ទងទៅកាន់រដ្ឋសាមីរបស់គេ ដោយមិនមានការគៀបសង្កត់ រឹតត្បិតនិងរំលោភបំពានពីសំណាក់រដ្ឋម្ចាស់ផ្ទះឡើយ។ ផ្ទុយទៅវិញ រដ្ឋម្ចាស់ផ្ទះត្រូវធានាផ្តល់ឱ្យនូវសេរីភាពយ៉ាងពេញលេញនិងមានប្រសិទ្ធភាពក្នុងការធ្វើទំនាក់ទំនងរវាងស្ថានទូតនិងរដ្ឋសាមីរបស់គេ ឬរវាងស្ថានទូត និងភ្នាក់ងារដែលបម្រើការនៅក្នុងរដ្ឋម្ចាស់ផ្ទះជាមួយគ្នា ដូចជាស្ថានកុងស៊ុលនៃរដ្ឋដាក់ទូតនោះជាដើម។ តែក្នុងករណីពិសេសមួយចំនួន ត្រូវរង់ចាំការអនុញ្ញាពីរដ្ឋម្ចាស់ផ្ទះជាមុនសិនទើបអាចអនុវត្តបានដូចជា ការដំឡើង និងប្រើប្រាស់គ្រឿងបញ្ជូនសារជាដើម។

យោងតាមមាត្រា២៧ នៃអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត បានចែងដូចតទៅៈ

១. រដ្ឋម្ចាស់ផ្ទះ អនុញ្ញាតនិងការពារការទាក់ទងដោយសេរីរបស់បេសកកម្មការទូតសម្រាប់គ្រប់ទិសដៅជាផ្លូវការ។ ក្នុងការទាក់ទងជាមួយរដ្ឋាភិបាល ក៏ដូចជាមួយបេសកកម្មការទូតនិងស្ថានកុលស៊ុលដទៃទៀតរបស់រដ្ឋដាក់ទូតទោះតាំងនៅទីណាក៏ដោយ បេសកកម្មអាចប្រើប្រាស់គ្រប់មធ្យោបាយសមស្របរួមទាំងហារីទូត និងសារលិខិតជាសម្ងាត់ ឬជាលេខ។ ប៉ុន្តែបេសកកម្មការទូតអាចដំឡើងនិងប្រើប្រាស់គ្រឿងបញ្ជូនសារបាន លុះត្រាណាតែមានការយល់ព្រមពីរដ្ឋផ្ទះ។

២. ការឆ្លើយឆ្លងជាផ្លូវការរបស់បេសកកម្មការទូត មិនអាចត្រូវបំពារបំពានបានឡើយ។ ការឆ្លើយឆ្លងជាផ្លូវការ សំដៅរាល់ការឆ្លើយឆ្លង ដែលពាក់ព័ន្ធដល់បេសកកម្មការទូតនិងមុខងាររបស់បេសកកម្មការទូត។

៣. ហិបទូត មិនអាចត្រូវបើក ឬឃាត់ទុកបានឡើយ។

៤. កញ្ចប់ទាំងឡាយ ដែលផ្គុំជាហិបទូត ត្រូវមានសញ្ញាពីខាងក្រៅមើលឃើញច្បាស់បញ្ជាក់ពីលក្ខណៈជាហិបទូត ហើយអាចដាក់បាន តែឯកសារ ឬវត្ថុប្រើប្រាស់ជាផ្លូវការ។

៧. ហិបទូត អាចត្រូវប្រគល់ឱ្យទៅនាយអាកាសយានពាណិជ្ជកម្ម ដែលត្រូវចុះចតនៅចំណុចច្រកចេញចូលណាមួយ ដែលមានការអនុញ្ញាត។ នាយអាកាសយាននេះ ត្រូវកាន់ឯកសារផ្លូវការប្រាប់អំពីចំនួនកញ្ចប់ដុំជាហិបទូត ប៉ុន្តែមិនត្រូវបានចាត់ទុកជាហារីទូតទេ។ បេសកកម្មការទូត អាចបញ្ជូនសមាជិកម្នាក់របស់ខ្លួនឱ្យទៅទទួលយកហិបទូត ពីដៃនាយអាកាសយាន ដោយផ្ទាល់និងដោយសេរី។

ដូចមាននៅក្នុងមាត្រាខាងលើនេះ ចំពោះចំណុចទី៣ ទី៤និងទី៧ ហិបទូត សំដៅរាល់កញ្ចប់ ការបូប និងស្រោមសំបុត្រ ដែលមានផ្ទុកសំណុំឯកសារការទូតក្នុងទិសដៅប្រើប្រាស់សម្រាប់ប្រតិបត្តិការផ្លូវការរបស់រដ្ឋដាក់ទូត។ ហិបទូត មិនអាចត្រូវបានឆែកឆេរ បើកកកាយ ឬឃាត់ទុកដោយសំអាងមូលហេតុមិនសមស្រប

ឡើយ។ ជាលក្ខខណ្ឌ ហិបទូតនោះត្រូវតែមានសញ្ញាបញ្ជាក់ឱ្យបានច្បាស់លាស់ថាជាកម្មសិទ្ធិរបស់ស្ថានទូត ហើយមិនអាចនាំចូល ឬផ្ទុកអ្វីក្រៅពីឯកសារសម្រាប់ដំណើរការការទូតបានឡើយ។ ការកំណត់នេះ ជាភាពចាំបាច់សម្រាប់ការពារនូវផលប្រយោជន៍របស់រដ្ឋម្ចាស់ផ្ទះ។ ក្នុងករណីមួយចំនួន ដែលដាច់ខាតត្រូវទាមទារឱ្យមានការឆែកឆេរ គេផ្តល់សិទ្ធិឱ្យរដ្ឋម្ចាស់ផ្ទះអាចឆែកឆេរបាន ដោយត្រូវមានវត្តមាននូវតំណាងនៃភាគីទាំងសងខាងក្នុងការឆែកឆេរ គឺរដ្ឋម្ចាស់ត្រូវមានវត្តមានរដ្ឋមន្ត្រីក្រសួងការបរទេស ហើយស្ថានទូតត្រូវមានអ្នកតំណាងនៃបេសកកម្មនោះផ្ទាល់។ ករណីដាច់ខាតនេះ ត្រូវស្ថិតក្រោមមូលហេតុសង្ស័យយ៉ាងធ្ងន់ធ្ងរថា ហិបទូតនោះមានផ្ទុកនូវសម្ភារៈផ្សេងៗផ្ទុយនឹងចំណុច៤ នៃមាត្រាដដែលនេះដូចជា គ្រឿងសព្វាវុធ ឬសម្ភារៈដទៃទៀតដែលអាចនាំផលវិបាកធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាតិ នៃរដ្ឋម្ចាស់ផ្ទះ។ គួបផ្សំនឹងកត្តានេះ រដ្ឋទាំងឡាយគួប្បីត្រូវចង់ចាំថា ការបង្កើតឡើងនូវបុព្វសិទ្ធិ ដែលរដ្ឋមិនអាចបំពានបានចំពោះហិបទូតនេះ គឺមានសារៈសំខាន់ណាស់ទោះបីជាមានករណីលើកលែងដូចខាងលើក៏ដោយ។ ចំពោះចំណុចទី៧សំដៅបញ្ជាក់ថាអ្នកកាន់ហិបទូតជំនួសដែលជាអាកាសយានិក ច្បាប់មិនចាត់ទុកជាហារីការទូតរបស់ស្ថានទូតឡើយ ពោលគឺគ្រាន់តែជាអ្នកគ្រប់គ្រងហិបទូតបណ្តោះអាសន្នក្នុងពេល ដែលហិតទូតនោះស្ថិតនៅក្នុងការហោះហើររបស់គេប៉ុណ្ណោះ។[20] ក្រោយពីការចុះចត ហិបទូតនឹងត្រូវបានភ្នាក់ងារណាម្នាក់នៃស្ថានទូតមកទទួលយកដោយផ្ទាល់ពីអាកាសយានិកនោះ។[21]

### ៤. ចំពោះឯកត្តជនភាពនៃសមាជិកបេសកកម្ម ( Personal privileges )

ឯកត្តជនភាព(personal)នៃសមាជិកបេសកកម្មការទូត ជាភាពផ្ទាល់ខ្លួននៃសមាជិកការទូត។ ចំណុចនេះសំដៅបែងចែកថា តើសមាជិកការទូតអាចមានសិទ្ធិក្នុងការទទួលបានបុព្វសិទ្ធិផ្ទាល់ខ្លួនអ្វីខ្លះ អំពីមុខងាររបស់ខ្លួនក្នុងនាមជាមន្ត្រីការទូតប្រចាំនៅរដ្ឋម្ចាស់ផ្ទះ? ជាការសម្គាល់ សមាជិកការទូតក្នុងន័យនេះសំដៅទៅដល់រាល់សមាជិកទាំងឡាយនៃបេសកកម្មការទូតមានដូចជា ប្រមុខបេសកកម្ម សមាជិកនៃក្រុមបុគ្គលិកមន្ត្រីការទូត ដែលមានឋានន្តរសក្តិតែប៉ុណ្ណោះ។ ដោយឡែក សមាជិកនៃក្រុមរដ្ឋបាលនិងបច្ចេកទេសនិងសមាជិកនៃក្រុមសេវាកម្មមិនមានបុព្វសិទ្ធិអ្វីឡើយ ក្នុងក្របខ័ណ្ឌប្រទេសកម្ពុជា។

#### ៤. ១. ការជួយសម្រួល

ចំពោះសមាជិកបេសកកម្មក៏មានបុព្វសិទ្ធិដូចទីស្ថានដែរ គឺរដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចជួយសម្រួលនិងរកលំនៅស្ថានសម្រាប់ពួកគេ ប្រសិនបើគេជួបការលំបាកក្នុងការស្វែងរក។ យោងតាមវាក្យខ័ណ្ឌទី២ នៃមាត្រា

---

[20] Report of the International Commission (របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ) on multiple topics (ប្រធានបទចម្រុះ) ទំព័រទី១៣៨

[21] ដូចចំណុច[20]

២១របស់អនុសញ្ញាបានកំណត់ថា ប្រសិនបើចាំបាច់ រដ្ឋម្ចាស់ផ្ទះត្រូវជួយដល់បណ្ដាបេសកកម្មឱ្យបាននូវលំនៅស្ថានសមរម្យសម្រាប់សមាជិករបស់គេ។

**សម្គាល់** ស្របតាមវាក្យខ័ណ្ឌទី២ នៃមាត្រា៣៧ របស់អនុសញ្ញាទីក្រុងវៀនស្ដីពីទំនាក់ទំនងការទូត សមាជិកនៃក្រុមរដ្ឋបាលនិងបច្ចេកទេសនិង សមាជិកនៃក្រុមបុគ្គលិកសេវាកម្ម អាចទទួលបានបុព្វសិទ្ធិនេះ លុះត្រាតែគេមិនមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះ នោះរដ្ឋម្ចាស់ផ្ទះនឹងជួយសម្រួលក្នុងការស្វែងរកលំនៅស្ថាន។ ប៉ុន្តែកម្ពុជាបានបដិសេធមិនទទួលយកបញ្ញត្តិនេះ មកអនុវត្តនៅក្នុងក្របខ័ណ្ឌប្រទេសកម្ពុជាឡើយ។ ហេតុនេះ ទោះបីជាគេមាន ឬគ្មានសញ្ជាតិកម្ពុជា សមាជិកនៃការទូតស្ថិតក្នុងក្រុមរដ្ឋបាល បច្ចេកទេសនិងសមាជិកនៃក្រុមបុគ្គលិកសេវាកម្ម ដែលបំពេញភារកិច្ចនៅកម្ពុជាពុំទទួលបានបុព្វសិទ្ធិនេះឡើយ។

### ៤. ២. សេរីភាពក្នុងការធ្វើដំណើរ

ក្រៅពីការធ្វើការជួយសម្រួលក្នុងការស្វែងរកលំនៅស្ថាន បុព្វសិទ្ធិមួយប្រភេទទៀតមានសារៈសំខាន់ណាស់ គឺការផ្ដល់សេរីភាពពេញលេញក្នុងការធ្វើដំណើរដល់រាល់សមាជិកការទូតទាំងអស់ ទោះបីជាពួកគេធ្វើដំណើរក្នុងន័យបម្រើផលប្រយោជន៍បេសកកម្ម ឬក៏ដើម្បីភាពចាំបាច់ផ្ទាល់ខ្លួនក៏ដោយ។

តាមមាត្រា២៦ នៃអនុសញ្ញាបានចែងថា អាស្រ័យតាមច្បាប់និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះស្ដីពីតំបន់ ដែលការចេញចូលត្រូវហាមឃាត់ឬក៏ការចេញចូលត្រូវមានច្បាប់អនុញ្ញាតដោយហេតុទាក់ទងនឹងសន្តិសុខជាតិ រដ្ឋម្ចាស់ផ្ទះធានារ៉ាប់រងចំពោះគ្រប់បណ្ដាសមាជិកបេសកកម្មការទូត នូវសេរីភាពក្នុងការធ្វើដំណើរ និងការធ្វើចរាចរលើទឹកដីរបស់ខ្លួន។

ជាការពិតណាស់ កត្តាមួយក្នុងចំណោមកត្តាទាំងឡាយ ដែលសំដៅជួយសម្រួលដល់ប្រតិបត្តិការបេសកកម្មការទូត គឺការផ្ដល់ឱ្យរាល់សមាជិករបស់គេនូវសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើដំណើរមសម្រាប់ការងារក៏ដូចជាការកំសាន្តផងដែរ។ តែសេរីភាពក្នុងការដើរហើរក្នុងមាត្រា២៦ ខាងលើសំដៅបញ្ជាក់អំពីបញ្ហាមួយជាគោល ទាក់ទងនឹងករណីដែលរដ្ឋម្ចាស់ផ្ទះដាក់កំហិតការចេញចូលតំបន់ណាមួយក្នុងដែនដីរបស់គេ ក៏គេនៅធានាការដើរហើរបានដោយសេរីចំពោះភ្នាក់ងារការទូតដែរ។ ហើយការកម្រិតបិទតំបន់ណាមួយទៀតសោតក៏មិនត្រូវមានភាពដាច់ខាតពេកដែរ ពោលគឺត្រូវស្ថិតក្នុងកម្រិតសមល្មម ធានាការចេញចូល ធ្វើដំណើរឆ្លងកាត់ដោយសេរីដោយជាក់ស្ដែងនិងពិតប្រាកដ។

បើទោះជា មន្ត្រីការទូតមានបុព្វសិទ្ធិទូលំទូលាយបែបនេះក៏ដោយក៏នៅពេលខ្លះ ជាពិសេសក្នុងសម័យសង្គ្រាមត្រជាក់គេសង្កេតឃើញប្រទេសខ្លះបានកម្រិតសេរីភាពនៃការធ្វើដំណើររបស់មន្ត្រីទាំងនោះ។ បើទោះជាមន្ត្រីការទូតមានបុព្វសិទ្ធិទូលំទូលាយបែបនេះក៏ដោយក៏នៅពេលខ្លះ ជាពិសេសក្នុងសម័យសង្គ្រាមត្រជាក់គេសង្កេតឃើញប្រទេសខ្លះ បានកម្រិតសេរីភាពនៃការធ្វើដំណើររបស់មន្ត្រីទាំងនោះ។ ជាឧទាហរណ៍ ប្រទេស

កម្ពុជាក្នុងសម័យកាលអន្តរកាលចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ ដែលមានប៉ុលពតជាប្រមុខរាជរដ្ឋាភិបាលបាន ហាមឃាត់ដាច់ខាតក្នុងការធ្វើដំណើររបស់សមាជិកការទូតទាំងអស់ (លើកលែងតែអ្នកការទូតរបស់សាធារណរដ្ឋប្រជាមានិតចិនមួយប៉ុណ្ណោះ) និងតម្រូវឱ្យនៅក្នុងតំបន់ស្ថានទូត មិនឱ្យចេញពីតំបន់នោះដោយគ្មានការអនុញ្ញាតឡើយ។[22] នេះជាសកម្មភាពបំពានរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យទៅលើបុព្វសិទ្ធិរបស់អ្នកការទូត មានចែងក្នុងអនុញ្ញាទីក្រុងវៀង ដែលប្រទេសកម្ពុជាបានចូលជាភាគីតាំងតែពីឆ្នាំ១៩៦៣មកម្ល៉េះ។

**សម្គាល់** ស្របតាមវាក្យខ័ណ្ឌទី២ នៃមាត្រា៣៧របស់អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត សមាជិកនៃក្រុមរដ្ឋបាលនិងបច្ចេកទេសនិងសមាជិកនៃក្រុមបុគ្គលិកសេវាកម្មអាចទទួលបានបុព្វសិទ្ធិនេះ លុះត្រាតែគេមិនមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះនោះរដ្ឋម្ចាស់ផ្ទះនឹងធានាសេរីភាពក្នុងការធ្វើដំណើររបស់គេផងដែរ។ ប៉ុន្តែកម្ពុជាបានបដិសេធមិនទទួលយកបញ្ញត្តិនេះ មកអនុវត្តនៅក្នុងក្របខ័ណ្ឌប្រទេសកម្ពុជាឡើយ។ ហេតុនេះ សមាជិកនៃការទូតស្ថិតក្នុងក្រុមរដ្ឋបាល បច្ចេកទេសនិង សមាជិកនៃក្រុមបុគ្គលិកសេវាកម្ម ដែលបំពេញភារកិច្ចនៅកម្ពុជាពុំទទួលបានបុព្វសិទ្ធិនេះឡើយ ទោះបីជាគេមាន ឬគ្មានសញ្ជាតិកម្ពុជា។

### ៤. ៣. ភាពមិនអាចបំពារបំពានបាន

ភាពមិនអាចបំពារបំពានបានចំពោះភ្នាក់ងារការទូត មានបែងចែកជា ២ គឺភាពមិនអាចបំពារបំពានបានទៅលើរូបរាងកាយនិងភាពមិនអាចបំពារបំពានបានទៅលើលំនៅស្ថានរបស់គេ។

#### ៤. ៣. ១. រូបរាងកាយ

មិនខុសពី ភាពមិនអាចបំពារបំពានបានចំពោះទីស្ថាននិងប្រតិបត្តិការមុខងារការទូតនោះទេ ភ្នាក់ងារការទូតទទួលបានបុព្វសិទ្ធិ ដែលពុំមាននរណាអាចរំលោភបំពានសិទ្ធិរបស់គេដោយចាប់ឃុំឃាំង ឬចាប់ចងសេរីបានឡើយ។ ពួកគេត្រូវបានច្បាប់អន្តរជាតិផ្តល់ឱ្យនូវបុព្វសិទ្ធិនេះពេញលេញសម្រាប់ប្រសិទ្ធភាពការងារការទូត។ ទោះបីរដ្ឋទាំងពីរកំពុងមានជម្លោះក្តី រដ្ឋម្ចាស់ផ្ទះមិនមានសិទ្ធិចាប់ចងឃុំឃាំងភ្នាក់ងារការទូតណាម្នាក់ដោយយកលេសថា រដ្ឋាភិបាលរដ្ឋដាក់ទូតមានកំហុស ឬជាអ្នកបង្កជម្លោះនោះទេ។ បើរដ្ឋទាំងពីរ កំពុងស្ថិតក្នុងជម្លោះ អ្នកដែលគួរមានសេរីភាពជាងគេគឺភ្នាក់ងារការទូតរបស់រដ្ឋទាំងពីរ ព្រោះថាពួកគេជាអ្នកមានតួនាទីសម្រួលស្ថានការនិងទំនាក់ទំនងការទូតរវាងប្រទេសទាំងសងខាង ហើយលុះត្រាតែគេមានបុព្វសិទ្ធិមិនត្រូវបានបំពារបំពានចាប់ចង ទើបគេអាចអនុវត្តតួនាទីសម្របសម្រួលនេះបានជោគជ័យ។

ស្របតាមមាត្រា២៩ នៃអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតបានបញ្ជាក់ថា បុគ្គលដែលជាភ្នាក់ងារការទូតមិនអាចត្រូវបំពានបានទេ។ ភ្នាក់ងារទូតមិនអាចត្រូវបានចាប់ ឬឃុំខ្លួនតាមវិធានបែបណាមួយ

[22]សៀវភៅ ច្បាប់ការទូតរបស់បណ្ឌិត ស៊ា កុសល ឆ្នាំ១៩៩៩ ទំព័រទី៨០

បានឡើយ។ រដ្ឋម្ចាស់ផ្ទះទទួលស្វាគមន៍ភ្នាក់ងារការទូតដោយការគោរពនិងត្រូវចាត់គ្រប់វិធានការសមស្រប ដើម្បីរារាំង មិនឱ្យមានការបំពារបំពានណាមួយលើរូបរាងកាយសេរីភាពនិងសេចក្ដីថ្លៃថ្នូររបស់គេ។

ក្នុងបរិបទនៃបញ្ញត្តិខាងលើនេះ រដ្ឋម្ចាស់ផ្ទះមិនត្រឹមតែមិនអាចបំពារបំពាននោះទេ ផ្ទុយទៅវិញ ត្រូវចាត់វិធានការនានាសម្រាប់ធានាសុវត្ថិភាពសេរីភាពនិងភាពថ្លៃថ្នូររបស់ភ្នាក់ងារគ្រប់រូប។ រដ្ឋម្ចាស់ផ្ទះ ត្រូវទទួលស្វាគមន៍គេយ៉ាងពេញទី ក្នុងពេលដែលបានធ្វើដំណើរមកដល់រដ្ឋម្ចាស់ផ្ទះ។ រដ្ឋម្ចាស់ផ្ទះ ត្រូវតែធានារ៉ាប់រងដល់ទីបំផុត ដូចជា ស្វែងរកអ្នកយាមពិសេសដល់ភ្នាក់ងារការទូត ក្នុងករណីចាំបាច់។ បុព្វសិទ្ធិមិនអាចបំពារបំពានលើរូបរាងកាយនេះ មានតែចំពោះប្រមុខបេសកកម្មនិងសមាជិកនៃក្រុមមន្ត្រីការទូត ដែលមានឋានន្តរសក្តិប៉ុណ្ណោះ។

### ៤. ៣. ២. លំនៅស្ថាន

ចំពោះលំនៅស្ថានរបស់ភ្នាក់ងារការទូត ក៏ត្រូវបានការការពារដូចនឹងការការពារទីស្ថានបេសកកម្មដែរ។ មិនមានបុគ្គលណាមួយអាចបំពារបំពានចេញចូលដោយគ្មានការអនុញ្ញាត ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនៃលំនៅស្ថានរបស់គេបានឡើយ។ រដ្ឋម្ចាស់ផ្ទះត្រូវចាត់វិធានការនានាក្នុងការធានាសុខសន្តិភាព សុវត្ថិភាពនិងសេក្តីថ្លៃថ្នូរនៃលំនៅស្ថានរបស់ភ្នាក់ងារការទូត។

ស្របតាមមាត្រា៣០ នៃអនុសញ្ញាទីក្រុងវ៉ៀនស្តីពីទំនាក់ទំនងការទូតបានកំណត់ដូចជា៖

១. លំនៅស្ថានឯកជនរបស់ភ្នាក់ងារការទូត ក៏ទទួលបាននូវសិទ្ធិមិនអាចបំពារបំពានបាននិងការរក្សាការពារដូចទីស្ថានបេសកកម្មការទូតដែរ។

២. បណ្ដាឯកសារ ការឆ្លើយឆ្លងនិងទ្រព្យសម្បត្តិរបស់ភ្នាក់ងារ ក៏ទទួលបានសិទ្ធិមិនអាចបំពារបំពានបានដែរ។

បញ្ញត្តិនេះ ទាក់ទងនឹងភាពមិនអាចបំពារបំពានបានផ្សារភ្ជាប់ទៅនឹងលំនៅស្ថានឯកជន និងទ្រព្យសម្បត្តិរបស់ភ្នាក់ងារការទូត។ ទ្រព្យសម្បត្តិ ក្នុងន័យនេះសំដៅទៅលើ ចលនវត្ថុ ដែលស្ថិតនៅក្នុងលំនៅស្ថានរបស់គេរួមមាន គ្រឿងសង្ហារឹមជាដើម និងរបស់របរប្រើប្រាស់សម្រាប់ជាសេចក្ដីត្រូវការជាប្រចាំថ្ងៃដូចជា យានជំនិះ សៀវភៅធនាគារជាអាទិ៍ ត្រូវបានធានាការពារដោយច្បាប់ជានិច្ច។

### ៤. ៤. លិខិតឆ្លងដែនការទូត

ជាទូទៅ គេតែងយល់ថាលិខិតឆ្លងដែនមានតែមួយប្រភេទប៉ុណ្ណោះ ប៉ុន្តែមិនដូច្នោះទេ។ ដោយច្បាប់អន្តរជាតិបានផ្តល់សិទ្ធិពេញលេញដល់រដ្ឋអធិបតេយ្យទាំងអស់ឱ្យចេញលិខិតឆ្លងដែនទៅតាមសេចក្ដីត្រូវការរបស់គេ។ ក្នុងការអនុវត្តជាក់ស្តែង លិខិតឆ្លងដែនមានច្រើនប្រភេទណាស់ស្របតាមសេចក្តីសម្រេចរបស់

រាជរដ្ឋាភិបាលនៃបណ្តាប្រទេសនីមួយៗ។ ជាក់ស្តែង លិខិតឆ្លងដែនមានរហូតដល់ទៅ ៤ ប្រភេទ ដែលត្រូវបានប្រើប្រាស់ក្នុងក្របខ័ណ្ឌប្រទេសកម្ពុជា។ ស្របតាមមាត្រា១ នៃអនុក្រឹត្យលេខ៦៨ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា លិខិតឆ្លងដែនចែកចេញជា ៤ ប្រភេទ៖

ក. លិខិតឆ្លងដែនការទូត

ខ. លិខិតឆ្លងដែនផ្លូវការ

គ. លិខិតឆ្លងដែន (ធម្មតា)

ឃ. លិខិតធ្វើដំណើរ។

ក្នុងនោះ លិខិតឆ្លងដែនប្រភេទ ខ ចេញសម្រាប់មន្ត្រីរាជការទូទៅ ដែលត្រូវចេញទៅបំពេញបេសកកម្មជាផ្លូវការនៅបរទេស តែមិនមានជាបេសកកម្មការទូតឡើយ។ រីឯលិខិតឆ្លងដែនប្រភេទ គ ឬលិខិតឆ្លងដែនធម្មតាចេញសម្រាប់ពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅក្នុងគោលបំណងធ្វើដំណើរទៅបរទេស។ ចំណែកឯ លិខិតធ្វើដំណើរជាលិខិតផ្តល់ឱ្យជនដែលមិនមានសញ្ជាតិខ្មែរ ហើយបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដូចមានចែងក្នុងជំពូក ៤ នៃច្បាប់អន្តោប្រវេសន្ត។[23]

ចំពោះភ្នាក់ងារការទូតវិញ មានសិទ្ធិកាន់កាប់នូវលិខិតឆ្លងដែនប្រភេទ ក ដែលចេញដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ ក្នុងនោះ លិខិតឆ្លងដែនប្រភេទ ក ក៏ចេញសម្រាប់ព្រះរាជវង្សានុវង្ស ឥស្សរជន មន្ត្រីរាជការជាច្រើនផងដែរ ប៉ុន្តែពុំបានសេចក្តីថារាល់បុគ្គលដែលកាន់កាប់លិខិតឆ្លងដែនប្រភេទនេះនឹងទទួលបានបុព្វសិទ្ធិដូចជាភ្នាក់ងារការទូតនោះឡើយ។ ការផ្តល់ជូនបុព្វសិទ្ធិ ក្នុងលក្ខខណ្ឌដែលគេជាមន្ត្រីការទូត ឬជាបេសកជន ប្រេសិតពិសេស មន្ត្រីរដ្ឋាភិបាល ដែលកំពុងធ្វើដំណើរទស្សនៈកិច្ចជាផ្លូវការនៅកាន់រដ្ឋណាមួយ។ គេត្រូវចង់ចាំថា មានតែមន្ត្រីការទូតនិងបុគ្គលជាឥស្សរជនក្នុងដំណើរទស្សៈកិច្ចប៉ុណ្ណោះ ដែលទទួលបានបុព្វសិទ្ធិដូចមានចែងក្នុងអនុសញ្ញាទីក្រុងវ៉ៀន ដោយឡែកចំពោះបុគ្គលដទៃទៀតមិនមានបុព្វសិទ្ធិអ្វីឡើយ និងចាំបាច់ត្រូវគោរពតាមបទបញ្ញត្តិ ច្បាប់នានានៃរដ្ឋដែលខ្លួនកំពុងធ្វើដំណើរ។

សុពលភាពនៃលិខិតឆ្លងដែនការទូតមានរយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ហើយមិនអាចបន្តសុពលភាពបានទេ។[24] ចំពោះមន្ត្រីការទូតដែលចប់អាណត្តិបេសកកម្ម ពុំមានសិទ្ធិប្រើប្រាស់លិខិតឆ្លងដែនការទូតទៀតទេ។[25]

*គំរូនៃលិខិតឆ្លងដែន ៣ ប្រភេទគឺ ប្រភេទ ក ខនិង គ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ។*

[23] អនុក្រឹត្យលេខ៦៨ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤ មាត្រា៥ ៨និង១២

[24] អនុក្រឹតលេខ១១ ស្តីពីការផ្តល់និងការប្រើប្រាស់លិខិតឆ្លងដែនការទូតនិងផ្លូវការ ឆ្នាំ២០២០ មាត្រា៥

[25] ដូចចំណុច[24]

### ៤.៥. សមាជិកគ្រួសារ

សមាជិកគ្រួសារនៃមន្ត្រីការទូតដែលស្នាក់នៅក្នុងរដ្ឋម្ចាស់ផ្ទះ ទទួលបានបុព្វសិទ្ធិដូចជាមន្ត្រីការទូតដែរ។ ច្បាប់អន្តរជាតិបានផ្តល់ឱ្យសមាជិកគ្រួសារនៃមន្ត្រីការទូតនូវសេរីភាពក្នុងដំណើរ ភាពពុំអាចបំពារបំពានបានទាំងលើរូបរាងកាយនិងលំនៅស្ថានដែលគេកំពុងស្នាក់នៅ ពោលគឺជាលំនៅស្ថានរួមជាមួយមន្ត្រីការទូត។ ស្របតាមវាក្យខ័ណ្ឌទី១នៃមាត្រា៣៧របស់អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតបានកំណត់ថាសមាជិកគ្រួសាររបស់ភ្នាក់ងារការទូត ដែលរួមរស់នៅជាមួយភ្នាក់ងារទូត មានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិក្នុងមាត្រា២៩ដល់៣៦ ល្គឹកណាតែអ្នកទាំងនោះមិនមែនជាពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ។

លើសពីនេះ គេក៏មានសិទ្ធិកាន់កាប់នូវលិខិតឆ្លងដែនការទូតដូចគ្នានឹងមន្ត្រីការទូត បើយោងតាមមាត្រា២ នៃអនុក្រឹត្យលេខ៦៨ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤និងមាត្រា២ នៃអនុក្រឹតលេខ១១ ស្តីពីការផ្តល់និងការប្រើប្រាស់លិខិតឆ្លងដែនការទូតនិងផ្លូវការ ឆ្នាំ២០២០។ លក្ខខណ្ឌចាំបាច់ក្នុងការផ្តល់ជូននូវលិខិតឆ្លងដែនការទូតនេះ ត្រូវតែជាសហព័ទ្ធនិងកូនដែលក្រោម ១៨ឆ្នាំនៅលីវក្នុងបន្ទុកមន្ត្រីការទូតនោះ។

## ៥. មន្ត្រីការទូតមានសញ្ជាតិរដ្ឋម្ចាស់ផ្ទះ

ក្នុងករណីពិសេសណាមួយរដ្ឋដាក់ទូតសម្រេចតែងតាំងនូវភ្នាក់ងារការទូតរបស់ខ្លួន ដែលមានសញ្ជាតិម្ចាស់ផ្ទះ(មានសញ្ជាតិពីរ)គេអាចទទួលបានបុព្វសិទ្ធិ មិនអាចបំពារបំពានបានតែក្នុងពេលគេបំពេញបេសកកម្មការទូតប៉ុណ្ណោះ។ ដោយឡែក បុព្វសិទ្ធិផ្សេងៗទៀតស្ថិតលើការសម្រេចរបស់រដ្ឋម្ចាស់ផ្ទះជាអ្នកផ្តល់ឱ្យ។ តាមវាក្យខ័ណ្ឌទី១នៃមាត្រា៣៨របស់របស់អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតនោះ ភ្នាក់ងារការទូតដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះឬមានលំនៅស្ថានអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះមិនអាចបំពារបំពានបានតែសកម្មភាពផ្លូវការដែលបានបំពេញក្នុងការអនុវត្តមុខងាររបស់ខ្លួនតែប៉ុណ្ណោះ លើកលែងតែមានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិបន្ថែមទៀតដែលរដ្ឋម្ចាស់ផ្ទះផ្តល់ឱ្យ។

## ៦. សុពលភាពនៃបុព្វសិទ្ធិ

បុព្វសិទ្ធិទាំងឡាយសម្រាប់មន្ត្រីការទូតដូចមានចែងក្នុងអនុសញ្ញាទីក្រុងវៀន ឆ្នាំ១៩៦១ មានអនុភាពចាប់ពីពេលមន្ត្រីការទូតទាំងនោះមានធ្វើដំណើរមកដល់ទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ឬពេលដែលគេកាន់កាប់មុខតំណែង ឬប្រសិនបើជននោះស្ថិតក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះស្រាប់បុព្វសិទ្ធិទទួលបាននៅពេលមានការតែងតាំងជាផ្លូវការ (ជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួងការបរទេស ឬទៅកាន់ក្រសួងណាមួយដែលបានព្រមព្រៀងគ្នា) រហូតដល់មុខងាររបស់គេត្រូវបានបញ្ចប់និងចាកចេញផុតអំពីទឹកដីនៃរដ្ឋម្ចាស់ផ្ទះ។

ក្នុងករណីមានជម្លោះយោធា ក៏បុព្វសិទ្ធិមន្ត្រីការទូតនៅតែបន្តមានរហូតដល់ពេលខាងលើ។

រីឯករណី មានមរណភាពចំពោះមន្ត្រីការទូតក្តី ចំពោះសមាជិកគ្រួសារនៃមន្ត្រីការទូតក្តី(សមាជិកគ្រួសារដែលស្នាក់នៅក្នុងរដ្ឋម្ចាស់ផ្ទះ) គេនៅទទួលបានបុព្វសិទ្ធិពេញលេញរហូតដល់ចាកចេញផុតពីដែនដីរបស់រដ្ឋម្ចាស់ផ្ទះ។

# ជំពូកទី ៣
# អត្ថន័យឯកសិទ្ធិការទូត

# ជំពូកទី ៣
# អភ័យឯកសិទ្ធិការទូត

## ១. និយមន័យ

អភ័យឯកសិទ្ធិការទូត (diplomatic immunities) គឺរាល់សិទ្ធិទាំងឡាយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ឱ្យដល់ស្ថានបេសកកម្មការទូតនិងបុគ្គលិកទាំងឡាយរបស់បេសកកម្មការទូតនោះឱ្យរួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះដោយធានានូវភាពពុំអាចបំពារបំពានបាននិងការពារដល់ការអនុវត្តមុខងាររបស់បុគ្គលិកទាំងនោះ។

អភ័យឯកសិទ្ធិការទូតដាច់ខាត គឺជាអភ័យឯកសិទ្ធិពុំមែនត្រឹមតែមិនអនុញ្ញាតឱ្យមានការកាត់ទោស ឬការអនុវត្តសាលក្រមទៅលើការទូតប៉ុណ្ណោះទេ ថែមទាំងបានហាមឃាត់ការចាប់ផ្តើមនូវនីតិវិធីព្រហ្មទណ្ឌចំពោះអ្នកការទូតផងដែរដូចជា ការចេញដីកាកោះអញ្ជើញអ្នកការទូតឱ្យមកចូលរួមការជំនុំជម្រះក្តី ឬកោះអញ្ជើញឱ្យមកធ្វើជាកសិណសាក្សីជាដើម។

អភ័យឯកសិទ្ធិការទូត គឺជាទម្រង់មួយនៃអភ័យឯកសិទ្ធិស្របច្បាប់ដែលធានាថាអ្នកការទូតត្រូវបានផ្តល់ការឆ្លងកាត់ដោយសុវត្ថិភាព ហើយត្រូវបានគេចាត់ទុកថាមិនងាយនឹងមានបណ្តឹងឬការចោទប្រកាន់នៅក្រោមច្បាប់របស់ប្រទេសម្ចាស់ផ្ទះទោះបីជាពួកគេនៅតែត្រូវបានបណ្តេញចេញក៏ដោយ។ អភ័យឯកសិទ្ធិការទូតត្រូវបានកំណត់ជាច្បាប់អន្តរជាតិនៅក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូត (១៩៦១) ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសជាច្រើនលើកលែងតែប្រទេសមួយចំនួនតូចប៉ុណ្ណោះ។ ទស្សនៈនិងទំនៀមទំលាប់នៃអភ័យឯកសិទ្ធិការទូតមានតាំងពីរាប់ពាន់ឆ្នាំមកហើយ។ គោលការណ៍ជាច្រើននៃអភ័យឯកសិទ្ធិការទូតនាពេលបច្ចុប្បន្ននេះត្រូវបានគេចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់។ អភ័យឯកសិទ្ធិការទូតត្រូវបានបង្កើតឡើងដើម្បីអនុញ្ញាតឱ្យមានការថែរក្សាទំនាក់ទំនងរបស់រដ្ឋាភិបាល រួមទាំងអំឡុងពេលមានការលំបាកនិងជម្លោះប្រដាប់អាវុធ។ នៅពេលទទួលទូតដែលជាផ្លូវការតំណាងអធិបតេយ្យប្រមុខរដ្ឋទទួលបានការផ្តល់សិទ្ធិ និងអភ័យឯកសិទ្ធិមួយចំនួនដើម្បីធានាថាពួកគេអាចបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

## ២. ចំពោះទីស្ថាននៃបេសកកម្ម (The premises of the mission)

ដូចដែរបានរៀបរាប់នៅក្នុងចំណុចបុព្វសិទ្ធិការទូតដែរ ទីស្ថានបេសកកម្ម(premises)គឺជាដីធ្លី និងអាគារដែលសម្រាប់បម្រើការដល់បេសកកម្មការទូត ដោយរាប់បញ្ចូលទាំងនិវេសដ្ឋានរបស់ប្រមុខបេសកកម្មការទូតនោះផងដែរ ដែលបានចែងក្នុងមាត្រា២២នៃអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត។[26]

[26] អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា២២ វាក្យខ័ណ្ឌទី១

ជាគោលការណ៍ ភ្នាក់ងារអាជ្ញាធររបស់រដ្ឋម្ចាស់ផ្ទះត្រូវហាមឃាត់មិនអាចឱ្យចូលទៅក្នុងទីស្ថានបេសកកម្មនេះបានទេ។ ការហាមឃាត់នេះ ពុំមែនសំដៅតែនៅលើមន្ត្រីឬភ្នាក់ងារសមត្ថកិច្ចដូចជាភ្នាក់ងារនគរបាល ប៉ូលីស យោធា ឬភ្នាក់ងារគយប៉ុណ្ណោះទេ គឺសំដៅទៅលើភ្នាក់ងារទាំងអស់របស់រដ្ឋម្ចាស់ផ្ទះដោយរួមទាំងបុគ្គលសុរិយោដី ពន្លត់អគ្គីភ័យ រដ្ឋាករទឹក ជាដើម។ ការចេញចូលណាមួយនៃភ្នាក់ងារទាំងនោះអាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីប្រមុខបេសកកម្ម ឬអ្នកតំណាងរបស់គាត់។ ហេតុនេះ បើសិនជានៅក្នុងស្ថានទូត មានកើតឡើងនូវឧប្បត្តិហេតុណាមួយ ដូចជាអគ្គីភ័យ ជាដើម ភ្នាក់ងារពន្លត់អគ្គីភ័យរបស់រដ្ឋម្ចាស់ផ្ទះក៏ពុំអាចមានសិទ្ធិចេញចូលតាមទំនើងចិត្តទៅពន្លត់អគ្គីភ័យនៅទីនោះដោយគ្មានការអនុញ្ញាតពីប្រមុខបេសកកម្មនៃស្ថានទូតនោះបានដែរ។ មូលហេតុ ដែលច្បាប់កំណត់តឹងតែងបែបនេះព្រោះខ្លាចរដ្ឋម្ចាស់ផ្ទះប្រើមធ្យោបាយណាមួយ បង្ករជាអគ្គីភ័យឡើងដើម្បីជាលេសចូលទៅលួចឯកសារសម្ងាត់ទាំងឡាយដែលមាននៅក្នុងស្ថានបេសកកម្មក្នុងឱកាសកើតភាពវឹកវរនោះ។[27]

ក្រៅពីការហាមឃាត់ ពុំអនុញ្ញាតឱ្យភ្នាក់ងាររបស់រដ្ឋម្ចាស់ផ្ទះចូលទៅក្នុងទីស្ថានទូត ដោយគ្មានការយល់ព្រមពីស្ថានបេសកកម្មនោះរដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចពិសេសមួយទៀត គឺការពារទីស្ថានបេសកកម្មការទូតពីអំពើរុកគួនរំខានពីខាងក្រៅ ដូចជាការរារាំងមិនឱ្យបុគ្គលណាចូលទៅក្នុងស្ថានបេសកកម្មដោយគ្មានការអនុញ្ញាត ឬការពារកុំឱ្យមានការចោលគ្រឿងផ្ទុះទៅក្នុងទីស្ថានទូត។ ដើម្បីបំពេញកាតព្វកិច្ចខាងលើ រដ្ឋម្ចាស់ផ្ទះតែងតែបញ្ជូនភ្នាក់ងារនគរបាលខ្លួនទៅយាមជាប្រចាំនៅមុខនិងជុំវិញបរិវេណស្ថានទូតជានិច្ច។ នៅប្រទេសកម្ពុជាក៏មានអនុវត្តដែរ នៅក្នុងរាជធានីភ្នំពេញយើងតែងតែឃើញមាននគរបាលយាមនៅតាមស្ថានទូតនានា។ តាមមាត្រា២២ វាក្យខ័ណ្ឌទី២ ទីស្ថានបេសកកម្មការទូតមិនអាចត្រូវបានឆែកឆេរ ដកហូត ឬរឹបអូសបានឡើយ។[28]

– **ភាពពុំអាចបំពារបំពានបាន**

តាមច្បាប់អន្តរជាតិបុគ្គលិកនៃមន្ត្រីការទូតមិនអាចមានការបំពារបំពានបានឡើយ។ អាស្រ័យហេតុនេះ រដ្ឋម្ចាស់ផ្ទះជាទូទៅពុំមានសិទ្ធិឃុំឃាំង ឬឃាត់ខ្លួនមន្ត្រីការទូតបរទេសដែលកំពុងបំពេញបេសកកម្មនៅក្នុងទឹកដីខ្លួនបានទេ។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចរក្សាទំនាក់ទំនងជាប្រពៃនិងដោយគោរពចំពោះភ្នាក់ងារការទូតនិងស្ថានបេសកកម្មរបស់គេ ដោយមិនត្រូវប្រព្រឹត្តអំពើអ្វីដែលរារាំងដល់សកម្មភាពការងារស្របច្បាប់របស់អ្នកការទូតទាំងនោះ។ ក្រៅពីនេះ រដ្ឋម្ចាស់ផ្ទះមានភារកិច្ចផងដែរក្នុងការចាត់វិធានការសមស្រប

[27] សៀវភៅ ច្បាប់ការទូតរបស់បណ្ឌិត ស៊ា កុសល ឆ្នាំ១៩៩៩ ទំព័រទី៨១

[28] អនុសញ្ញាទីក្រុងវ្យែនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា២២ វាក្យខ័ណ្ឌទី២

ទាំងឡាយដើម្បីការពារ កុំឲ្យមានការរំលោភបំពានទៅលើបុគ្គលភាព ឬសេរីភាពនិងកិត្តិយសរបស់អ្នកការទូតទាំងនោះ។

**៣. ចំពោះដំណើរការនៃបេសកកម្ម** ( The work of the mission )

**៣. ១. អភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការរដ្ឋម្ចាស់ផ្ទះ**

តាមអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត ភ្នាក់ងារការទូតម្នាក់ៗមានអភ័យឯកសិទ្ធិដាច់ខាតរួចផុតទាំងស្រុងពីយុត្តាធិការព្រហ្មទណ្ឌរបស់រដ្ឋម្ចាស់ផ្ទះ ពោលគឺតុលាការនិង អាជ្ញាធរដទៃទៀតរបស់រដ្ឋម្ចាស់ផ្ទះគ្មានអំណាចចំពោះគ្រប់ករណីរបស់អ្នកការទូតនេះ ទោះបីជាគេបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរនិងក្នុងពេលវេលា ឬកាលៈទេសៈបែបណាក៏ដោយមានជាអាទិ៍ អំពើឃាតកម្ម ការធ្វើចារកម្មជាដើម។

អភ័យឯកសិទ្ធិដាច់ខាតរួចផុតទាំងស្រុងពីអំណាចយុត្តាធិការព្រហ្មទណ្ឌនៃរដ្ឋម្ចាស់ផ្ទះនេះ ពុំមែនត្រឹមតែមិនអនុញ្ញាតឱ្យមានការកាត់ទោស ឬការអនុវត្តសាលក្រមទៅលើអ្នកការទូតប៉ុណ្ណោះទេថែមទាំងបានហាមឃាត់នូវការចាប់ផ្តើមនៃនីតិវិធីព្រហ្មទណ្ឌចំពោះអ្នកការទូតទាំងនោះផងដែរ ដូចជាការចេញដីកាកោះហៅអ្នកការទូតឱ្យមកចូលរួមការជំនុំជម្រះក្តី ឬឱ្យមកធ្វើជាកសិណសាក្សីជាដើម។

ចំពោះករណីរឿងក្តីរដ្ឋប្បវេណី ភ្នាក់ងារការទូតម្នាក់ៗក៏មានអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះផងដែរ លើកលែងតែករណីដូចជាៈ[29]

- បណ្តឹងពាក់ព័ន្ធនឹងកម្មសិទ្ធិអសង្ហារឹមឯកជនដែលស្ថិតនៅលើទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ បើសិនជាភ្នាក់ងារការទូតនោះមិនកាន់កាប់អសង្ហារឹមនេះ ក្នុងនាមរដ្ឋដាក់ទូតនិងដើម្បីទិសដៅបេសកកម្មនោះ
- បណ្តឹងពាក់ព័ន្ធនឹងមរតក ដែលក្នុងនោះភ្នាក់ងារការទូតជាអ្នកប្រតិបត្តិតាមមរតកសាសន៍ ជាអ្នកគ្រប់គ្រងជាអ្នកទទួលមរតក ឬជាអ្នកទទួលអច្ច័យទាន ក្នុងនាមជាឯកជនហើយមិនមែនក្នុងនាមជារដ្ឋដាក់ទូត
- បណ្តឹងពាក់ព័ន្ធនឹងសកម្មភាពវិជ្ជាជីវៈ ឬពាណិជ្ជកម្មដែលភ្នាក់ងារការទូតធ្វើនៅក្នុងរដ្ឋម្ចាស់ផ្ទះក្រៅពីមុខងារផ្លូវការរបស់ខ្លួន។

រដ្ឋដាក់ទូតអាចបោះបង់ អភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិការសម្រាប់ភ្នាក់ងារការទូតនិង ជនទាំងឡាយដែលទទួលនូវអភ័យឯកសិទ្ធិដែលក្នុងមាត្រា៣៧ ។ ការបោះបង់នេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ប្រសិនបើអ្នកការទូតណាម្នាក់ ឬជនម្នាក់ដែលទទួលអភ័យឯកសិទ្ធិ ចំពោះអំណាចយុត្តាធិការតាមមាត្រា៣៧ដាក់ពាក្យបណ្តឹងទៅតុលាការភ្នាក់ងាររូបនោះនឹងអស់សិទ្ធិលើកសំអាងពីអភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិ-

[29] សៀវភៅ ច្បាប់ការទូតរបស់បណ្ឌិត ស៊ា កុសល ឆ្នាំ១៩៩៩ ទំព័រទី៥០

ការលើពាក្យបណ្ដឹងតបវិញដែលទាក់ទងដោយផ្ទាល់ទៅនឹងពាក្យបណ្ដឹងដើម។ម្យ៉ាងវិញទៀត ការបោះបង់អភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិការលើបណ្ដឹងផ្នែករដ្ឋប្បវេណីឬរដ្ឋបាល មិនត្រូវចាត់ទុកជាការបោះបង់អភ័យឯកសិទ្ធិចំពោះវិធានការអនុវត្តសាលក្រមឡើយ។ ការបោះបង់អភ័យឯកសិទ្ធិបែបនោះចាំបាច់ត្រូវធ្វើការបដិសេធមួយដាច់ដោយឡែក។[30]

ឧទាហរណ៍ ៖ បុគ្គលិកជាជនជាតិអាល៊ឺម៉ង់ដែលបានបំពេញបេសកកម្មការទូតប្រចាំប្រទេសរុស្ស៊ីបានបើករថយន្តទៅបុកប្រជាពលរដ្ឋរុស្ស៊ី ហើយក្រោយមកបើករត់ចូលស្ថានទូតអាល៊ឺម៉ង់ប្រចាំប្រទេសរុស្ស៊ី។ ទោះបីជាពេលកើតហេតុភ្លាមមាននគរបាលរុស្ស៊ីដល់កន្លែងក៏ដោយ ក៏ពួកគេពុំមានសិទ្ធិចាប់ខ្លួន ឃុំឃាំងទៅលើបុគ្គលិករូបនោះទេ ។ ក្រោយមកក្រសួងការបរទេសរុស្ស៊ីបានដាក់ពាក្យស្នើទៅស្ថានទូតអាល៊ឺម៉ង់ ដើម្បីធ្វើការដកអភ័យឯកសិទ្ធិពីបុគ្គលនោះដើម្បីធ្វើការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ តែត្រូវបានប្រមុខបេសកកម្មនៃទូតអាល៊ឺម៉ង់ប្រានចោល ដោយមិនទទួលស្គាល់នូវអ្វីដែលខាងរដ្ឋម្ចាស់ផ្ទះ (រុស្ស៊ី) ។ ខាងស្ថានទូតអាល៊ឺម៉ង់បានឆ្លើយតបទៅវិញ ចំពោះការចោទប្រកាន់នេះមិនត្រឹមត្រូវទេ ដោយពេលកើតហេតុបុគ្គលនោះកំពុងបំពេញការងារនៅក្រសួងការបរទេសខ្លួននៅឯប្រទេសអាល៊ឺម៉ង់វាមិនពិតដូចជាខាងភាគីរុស្ស៊ីលើកឡើងទេ។ បើទោះបីជាមានភស្តុតាងច្បាស់លាស់ក៏ដោយ ក៏ខាងភាគីអាល៊ឺម៉ង់នៅតែប្រានចោលការចោទប្រកាន់នេះ។

តាមឧទាហរណ៍ខាងលើ ជនណាដែលប្រព្រឹត្តអំពើបែបនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារនឹងសងជាព្យសនកម្មព្រោះជាបទឧក្រិដ្ឋ។ តែដោយសារ ជនដែលជាប់សង្ស័យប្រព្រឹត្តបទល្មើសនេះជាមន្ត្រីការទូត តុលាការរបស់រដ្ឋម្ចាស់ផ្ទះពុំត្រឹមតែគ្មានសិទ្ធិអំណាចជំនុំជម្រះ ចេញសាលក្រមដាក់ទោសលើបុគ្គលនោះប៉ុណ្ណោះទេ សូម្បីតែចេញដីកាចោទប្រកាន់ទៅលើបុគ្គលរូបនេះដើម្បីជាកិច្ចចាប់ផ្ដើម នៃការអនុវត្តនីតិវិធីព្រហ្មទណ្ឌ ក៏តុលាការរដ្ឋម្ចាស់ផ្ទះមិនមានអំណាច អាចប្រព្រឹត្តទៅបានផងដែរ។ មិនតែប៉ុណ្ណោះ នគរបាលនៃរដ្ឋម្ចាស់ផ្ទះ គ្មានសិទ្ធិអាចចាប់ខ្លួន ឬ ធ្វើការឆែកឆេរមន្ត្រីការទូត ឬទីស្ថានទូតនៃបុគ្គលនោះបានឡើយ។

ជាឧទាហរណ៍ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ អគ្គរដ្ឋទូតរុស្ស៊ីលោក Andrei Karlov ត្រូវបានខ្មាំងកាំភ្លើង **Mevlüt Mert Altıntaş** ជនជាតិតួគីបាញ់សម្លាប់នៅខណៈពេលដែលគាត់ធ្វើការទស្សនៈកិច្ចពិព័រណ៍សិល្បៈនៅប្រទេសតួគីក្នុងពេលបំពេញបេសកកម្មការទូតប្រចាំប្រទេសតួគី។ យោងតាមសាក្សីដែលនៅកន្លែងកើតហេតុបានអោយដឹងថា ខ្មាំងកាំភ្លើងរូបនេះបានបន្លំខ្លួនជាអង្គរក្សរបស់អគ្គរដ្ឋទូតនោះ នៅពេលដែលលោក Andrei Karlov កំពុងនិយាយ Mevlüt Mert Altıntaş បានដកកាំភ្លើងបាញ់ទៅលើលោកបណ្ដាអោយរងរបួសធ្ងន់ហើយបានស្លាប់ក្រោយពេលបញ្ជូនទៅមន្ទីរពេទ្យ។ យោងតាមការស៊ើបអង្កេតជនល្មើសរូបនោះជា ប៉ូលីសតួគី

[30] អនុសញ្ញាទីក្រុងវៀននស្ដីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៣២

ដែលត្រូវបានគេបាញ់សម្លាប់នៅនឹងកន្លែងកើតហេតុ។ ក្រោយពេលកើតហេតុ ប្រធានាធិបតីរុស្សីលោក Valdimir Putin បានសម្តែងនូវមតិថា ការសម្លាប់អគ្គរដ្ឋទូតរុស្សីនេះ គឺជាការប្រព្រឹត្តបទឃាតកម្មដែលជាអំពើនៃការបង្ក ហេតុដើម្បីរារាំងដល់ទំនាក់ទំនងរុស្សី និងតួគី ចំណែកឯប្រធានាធិបតីតួគីក៏បានបញ្ជាក់ផងដែរថា ករណីឃាតកម្មនេះគឺជាការបង្កជម្លោះដល់រដ្ឋទាំងពីរ។

តាមអនុសញ្ញាទីក្រុងវៀននស្តីពីទំនាក់ទំនងការទូត មាត្រា២៩ បុគ្គលភ្នាក់ងារការទូត មិនអាចត្រូវបំពារបំពានទាំងសេចក្តីថ្លៃថ្នូរ និងទៅលើរូបរាងកាយ។

## ៣. ២. ទស្សនៈយល់ច្រលំមួយចំនួនចំពោះការផ្តល់អភ័យឯកសិទ្ធិការទូត

មានទស្សនៈមួយចំនួនតែងតែយល់ច្រលំថា ការផ្តល់អភ័យឯកសិទ្ធិបែបនេះ គឺជាការលើកតម្កើងជនបរទេសដែលបណ្តាលឱ្យជនបរទេសទាំងនោះ មានសិទ្ធិច្រើនជាងពលរដ្ឋម្ចាស់ស្រុក។ ដើម្បីបកស្រាយចំពោះទស្សនៈនេះយើងត្រូវចោទសួរវិញថា បើមន្ត្រីការទូតទាំងនេះគ្មានអភ័យឯកសិទ្ធិបែបនេះទេ តើពួកគេអាចអនុវត្តមុខងាររបស់ពួកគេជាតំណាងរដ្ឋអធិបតេយ្យបានដែរឬទេ?

តើតំណាងរដ្ឋដាក់ទូតមួយអាចចរចាដោយស្មើរភាពជាមួយ តំណាងរដ្ឋម្ចាស់ផ្ទះបានទេ បើគេស្ថិតក្នុងស្ថានភាពភ័យខ្លាចអំណាចនិងការផ្តន្ទាទោសពីរដ្ឋម្ចាស់ផ្ទះបែបនោះ ព្រោះថាបើគេគ្មានអភ័យឯកសិទ្ធិនោះទេ អំពើនឹងពាក្យសម្តីរបស់ពួកគេ អាចត្រូវរដ្ឋម្ចាស់ផ្ទះជាអំពើដែលអាចមានទោសរហូតដល់ប្រហារជីវិតថែមទៀតផង។ តាមគោលការណ៍ច្បាប់ រដ្ឋឯករាជ្យនីមួយៗសុទ្ធជារដ្ឋអធិបតេយ្យដែលមានអំណាចនិង តួនាទីធំជាងគេ មិននៅក្រោមអំណាចរបស់រដ្ឋណាមួយផ្សេងទៀតឡើយ។ ដោយសាររដ្ឋអធិបតេយ្យនីមួយៗមានសមភាពរវាងគ្នានឹងគ្នាតាមផ្លូវច្បាប់ ដូចបានចែងក្នុងមាត្រា១ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ហេតុនេះ នៅពេលដាក់ទូតបញ្ជូនបេសកកម្មរបស់ខ្លួនទៅរដ្ឋម្ចាស់ផ្ទះតំណាងនេះ មិនអាចស្ថិតក្រោមអំណាចរបស់រដ្ឋម្ចាស់ផ្ទះបានឡើយ។ ដើម្បីធានាគោលការណ៍នេះ គេចាំបាច់ត្រូវផ្តល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ដល់ជនដែលជាតំណាងរដ្ឋទាំងនោះ។

ម្យ៉ាងទៀត យើងដឹងថាតាមគោលការណ៍យុត្តាធិការដែនដី រាល់ជនបរទេសទាំងអស់ដែលកំពុងមានវត្តមាននៅក្នុងរដ្ឋមួយ ត្រូវស្ថិតនៅក្រោមអំណាចនៃរដ្ឋនោះ។ បើគ្មានការផ្តល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិការទូតនោះទេ បុគ្គលិកនៃស្ថានបេសកកម្មទាំងអស់ ដោយរាប់បញ្ចូលទាំងឯកអគ្គរដ្ឋទូតផងដែរ ដែលជាតំណាងនៃរដ្ឋដាក់ទូត ក៏ត្រូវតែស្ថិតក្រោមអំណាចរបស់រដ្ឋម្ចាស់ផ្ទះដែរ គឺរដ្ឋម្ចាស់ផ្ទះមានសិទ្ធិចាប់ឃុំឃាំង កាត់ទោស ផ្តន្ទាទោសដាក់ពន្ធនាគារ។ បើតំណាងរដ្ឋដាក់ទូតស្ថិតក្រោមអំណាចនៃរដ្ឋម្ចាស់ផ្ទះបែបនេះ តើឯណាទៅអធិបតេយ្យភាពនិងឯករាជ្យភាពនៃរដ្ឋដាក់ទូត និងសមភាពនៃរដ្ឋដាក់ទូតនឹងរដ្ឋម្ចាស់ផ្ទះ? តើតំណាងរដ្ឋដាក់ទូតអាចចរចាដោយស្មើ-រភាព ឬការពារអត្ថប្រយោជន៍របស់រដ្ឋខ្លួនបានដែរឬទេ?

ហេតុដូច្នេះហើយ បានជារដ្ឋទាំងឡាយបានព្រមព្រៀងគ្នាបង្កើតឲ្យមានច្បាប់អន្តរជាតិកំណត់ឱ្យមានការផ្តល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិខាងលើដល់សមាជិកបេសកកម្មទាំងឡាយ ព្រោះបើពុំមានការផ្តល់បែបនេះទេ ជនទាំងនោះមិនអាចបំពេញដោយមានប្រសិទ្ធភាពនូវមុនងារជាតំណាងរដ្ឋដាក់ទូតមួយ ដែលមានអធិបតេយ្យភាពនិងឯករាជ្យពេញលេញបានទេ។ តែផ្តល់បែបនេះពុំមែនបានសេចក្តីថា បុគ្គលទាំងនោះអាចធ្វើអ្វីបានស្រេចតែតាមអំពើចិត្តនៅក្នុងទឹកដីរបស់រដ្ឋម្ចាស់ផ្ទះនោះទេ។ ពួកគេទាំងនោះត្រូវមានកាតព្វកិច្ច ដូចចែងក្នុងមាត្រា៤១ នៃអនុញ្ញាទីក្រុងវៀននស្តីពីទំនាក់ទំនងការទូត គឺត្រូវគោរពច្បាប់និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះនឹងត្រូវបោះបង់ នូវរាល់អំពើទាំងឡាយណាដែលជាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋម្ចាស់ផ្ទះ។[31] មិនតែប៉ុណ្ណោះ បុគ្គលទាំងនេះគ្មានសិទ្ធិធ្វើអាជីវកម្មរកស៊ី ឬប្រកបមុខរបរវិជ្ជាជីវៈយកកម្រៃផ្ទាល់ខ្លួន នៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះបានឡើយ។

ការផ្តល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងនេះពុំមែនជា ការផ្តល់ឱ្យដើម្បីជាអត្ថប្រយោជន៍ដល់ក្រុមជន ឬបុគ្គលណាមួយឱ្យពិសេសនោះទេ គឺគ្រាន់តែជាការផ្តល់ទៅឱ្យតំណាងរដ្ឋ ដើម្បីធានាអធិបតេយ្យភាពនិងឯករាជ្យភាពរវាងរដ្ឋនិងរដ្ឋតែប៉ុណ្ណោះ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេសង្កេតឃើញមានថាទំនោរ នៅក្នុងសហគមន៍អន្តរជាតិទទួលស្គាល់នូវសិទ្ធិរបស់រដ្ឋម្ចាស់ផ្ទះអាចឃាត់ ឬឃុំខ្លួនអ្នកការទូតបានរយៈពេលមួយរយៈខ្លីដែរ បើសិនអ្នកការទូតនោះកំពុងរៀបចំ ឬកំពុងប្រព្រឹត្តិជាក់ស្តែងនូវបទឧក្រិដ្ឋធ្ងន់ធ្ងរណាមួយ ហើយការឃាត់ឃាំងនោះគឺជាការរារាំងមិនឱ្យគេប្រព្រឹត្តអំពើនោះតទៅទៀតនោះ។[32]

## ៤. អភ័យឯកសិទ្ធិរបស់ភ្នាក់ងារដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះនិងសមាជិកគ្រួសារក្រុមបុគ្គលិកដទៃទៀត នៃបេសកកម្មការទូត

- **អភ័យឯកសិទ្ធិភ្នាក់ងារការទូតមានសញ្ជាតិរដ្ឋម្ចាស់ផ្ទះ**

ដោយមូលហេតុពិសេសណាមួយ គេសង្កេតឃើញថាក្នុងករណីខ្លះ រដ្ឋដាក់ទូតបានសម្រេចចាត់តាំងឱ្យពលរដ្ឋរបស់ខ្លួន ដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះផង (មានសញ្ជាតិ២) ឱ្យទៅធ្វើជា ឯកអគ្គរដ្ឋទូត ឬមន្ត្រីការទូតប្រចាំនៅរដ្ឋម្ចាស់ផ្ទះនោះ។ ជាទូទៅ អ្នកការទូតបែបនេះអាចទទួលបាន នូវសិទ្ធិរួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះតែនៅក្នុងពេលដែលខ្លួនកំពុងធ្វើសកម្មភាពកិច្ចការផ្លូវការតែប៉ុណ្ណោះ។[33] ជាការពិតណាស់រដ្ឋម្ចាស់

[31] អនុសញ្ញាទីក្រុងវៀននស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៤១

[32] សៀវភៅ ច្បាប់ការទូតរបស់បណ្ឌិត ស៊ា កុសល ឆ្នាំ១៩៩៩ ទំព័រទី៥៤

[33] អនុសញ្ញាទីក្រុងវៀននស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៣៨ វាក្យខ័ណ្ឌទី១

ផ្ទះមានសិទ្ធិអាចផ្តល់នូវបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិបន្ថែមទៀតដល់អ្នកការទូតបែបនេះបានអាស្រ័យតាមមនោសញ្ចេតនានិងការយល់ឃើញរបស់រដ្ឋនោះ។

- **អភ័យឯកសិទ្ធិរបស់សមាជិកគ្រួសារ**

តាមអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត សមាជិកគ្រួសារក្រុមបុគ្គលិករដ្ឋបាលនិងបច្ចេកទេសនៃបេសកកម្មការទូត ក៏មានអភ័យឯកសិទ្ធិស្រដៀងគ្នានឹងភ្នាក់ងារការទូតដែរ លើកលែងតែអភ័យឯកសិទ្ធិរួចផុតពីអំណាចយុត្តាធិការ រដ្ឋប្បវេណីនិងរដ្ឋបាលដែលរដ្ឋម្ចាស់ផ្ទះផ្តល់ជូនចំពោះករណី ដែលទាក់ទងនឹង សកម្មភាពបំពេញមុខងារផ្លូវការរបស់អ្នកទាំងនោះតែប៉ុណ្ណោះ។[34] ជាទូទៅ គេរាប់បញ្ចូលទៅក្នុងសមាជិកគ្រួសារ មានស្វាមី ឬភរិយា របស់អ្នកការទូតនោះ ព្រមទាំងកូននៅលីវទាំងឡាយ ដែលមានអាយុក្រោម១៨ឆ្នាំនិងសាច់ញាតិគ្រួសារដទៃទៀតដែលស្ថិតក្នុងបន្ទុកផ្ទាល់របស់អ្នកការទូត។

## ៥. ភាតព្វកិច្ចគោរពច្បាប់រដ្ឋម្ចាស់ផ្ទះនិង វិធានការ Persona Non Grata

សមាជិកទាំងអស់ចាំបាច់ត្រូវតែគោរពតាមវិធានច្បាប់របស់រដ្ឋម្ចាស់ផ្ទះ ក្នុងកម្រិតដែលមិនប៉ះពាល់ដល់សិទ្ធិការទូតរបស់គេ។ តាមវាក្យខ័ណ្ឌទី១និងទី២ នៃមាត្រា៤១ របស់អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត បានកំណត់ថា៖

១. ដោយគ្មានធ្វើឱ្យប៉ះពាល់ ដល់(បុព្វសិទ្ធិនិងអភ័យឯក)សិទ្ធិរបស់គេ បុគ្គលទាំងឡាយដែលមាន(បុព្វសិទ្ធិនិងអភ័យឯក)សិទ្ធិនេះមានកាតព្វកិច្ច គោរពច្បាប់និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះ។ បុគ្គលទាំងនោះក៏មានកាតព្វកិច្ចមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋម្ចាស់ផ្ទះនោះផងដែរ។

២. រាល់កិច្ចការផ្លូវការទាំងអស់ ដែលរដ្ឋដាក់ទូត ប្រគល់ឱ្យបេសកកម្មការទូតដោះស្រាយជាមួយរដ្ឋម្ចាស់ផ្ទះ ត្រូវតែដោះស្រាយជាមួយ ឬតាមរយៈក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ឬក៏ក្រសួងដទៃទៀត ដែលបានព្រមព្រៀងគ្នា។

ជាទូទៅ ភ្នាក់ងារការទូតដែលមកពីប្រទេសនានាភាគច្រើនលើសលុបជាបុគ្គលមានចំណេះដឹងនិងមានចរិយាមាយាទល្អ ដែលត្រូវបានរដ្ឋសាមីខ្លួនចាត់ឱ្យមកដំណើរការជាតំណាងរដ្ឋរបស់ខ្លួន។ ភ្នាក់ងារការទូតនោះ មិនត្រូវអនុវត្តសិទ្ធិរបស់ខ្លួនដោយដាច់ស្រេចតែចិត្តរបស់គេនោះទេ។ បុគ្គលទាំងនោះត្រូវចងចាំថា ពិតមែនតែរដ្ឋម្ចាស់ផ្ទះបានផ្តល់អភ័យឯកសិទ្ធិដល់រូបគេ រួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះក៏ដោយ ក៏បុគ្គលទាំងនោះមានកាតព្វកិច្ចគោរពច្បាប់ទាំងឡាយដែលស្ថិតជាធរមានរបស់រដ្ឋម្ចាស់ផ្ទះដែរ។[35] ក្នុងភាពជាក់ស្តែង

[34] អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៣៧ វាក្យខ័ណ្ឌទី២

[35] អនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៤១

មានករណីតែតិចតួចប៉ុណ្ណោះដែលបុគ្គលអ្នកការទូតខ្លះ ឬសមាជិកគ្រួសាររបស់ពួកគេមានជាប់ពាក់ព័ន្ធទៅនឹងបទល្មើសព្រហ្មទណ្ឌ នៅក្នុងប្រទេសម្ចាស់ផ្ទះ ហើយករណីដែលកើតភាគច្រើននោះ គឺច្រើនតែជាបទល្មើសចរាចរណ៍ដូចជា បើកបរហួសល្បឿនកំណត់ ឬបើកបរក្នុងពេលស្រវឹងជាដើម។

សរុបមក ភ្នាក់ងារការទូត មានកាតព្វកិច្ចគោរពច្បាប់ប្រទេសជាម្ចាស់ផ្ទះ ព្រមទាំងអនុវត្តកិច្ចការងារដែលរដ្ឋសាមីរបស់ខ្លួនបានបញ្ជូនមក និងជានិច្ចជាកាលប្រាស្រ័យទាក់ទងជាមួយក្រសួងដែលពាក់ព័ន្ធក្នុងកិច្ចការឱ្យបានល្អប្រសើរ។ ជាទូទៅ ការធ្វើទំនាក់ទំនងការបរទេសរមែងពាក់ព័ន្ធជាមួយនឹងកិច្ចការនៃប្រទេសមួយដូចជា មុខងារក្នុងការផ្តល់ព័ត៌មាននិងសរសេររបាយការណ៍ ដែលតែងតែកត់ត្រានូវរាល់ព្រឹត្តិការណ៍ជាតិសំខាន់ៗ ដែលកើតមានឡើងក្នុងរដ្ឋម្ចាស់ផ្ទះ។ ជាក់ស្តែង ដូចបានបង្ហាញក្នុងចំណុច មុខងារផ្តល់ព័ត៌មានស្រាប់ សហរដ្ឋអាមេរិកបានធ្វើរបាយការណ៍ជាប្រចាំអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដល់រដ្ឋាភិបាលរបស់គេ ហើយជារឿយៗអ្នកនាំពាក្យរបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា តែងអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់អំពីបញ្ហានេះ ឬហួតដល់ចាប់ផ្តើមរិះគន់ពីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សផងដែរ។ ទោះជាតិច ឬច្រើនក្តី ទង្វើនេះអាចជាសកម្មភាព ដែលសហរដ្ឋអាមេរិកចង់ជ្រៀតចូលក្នុងសេចក្តីសម្រេចរបស់រដ្ឋាភិបាលនៃរដ្ឋអធិបតេយ្យមួយ។ ហេតុដូច្នេះហើយ ក្នុងប្រតិបត្តិការមុខងារនានា ភ្នាក់ងារការទូតត្រូវតែប្រាកដថាខ្លួនមិនបានជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋម្ចាស់ផ្ទះជាដាច់ខាត។ ឧទាហរណ៍មួយផ្សេងទៀត គឺបេសកកម្មការទូតទាំងអស់ (ភ្នាក់ងារចូលរួមផ្ទាល់ក្តី ការតាំងបង្ហាញស្លាកយុទ្ធនាការនៅស្ថានទូតក្តី) មិនអាចចូលរួមក្នុងយុទ្ធនាការទាមទារណាមួយពាក់ព័ន្ធនឹងបញ្ហានយោបាយរបស់រដ្ឋម្ចាស់ផ្ទះឡើយ។

មួយវិញទៀត ក្នុងករណី មន្ត្រីការទូតមិនបានគោរពបញ្ញត្តិច្បាប់របស់រដ្ឋម្ចាស់ផ្ទះ ហើយនាំឱ្យមានព្យសនកម្មណាមួយ ក៏គេត្រូវបានរួចផុតពីការចាប់ឃុំឃាំងនិងការកាត់ក្តីតាមប្រព័ន្ធតុលាការ (អភ័យឯកសិទ្ធិអំពីអំណាចយុត្តាធិការ)។ ពោល បើទោះបីជាយ៉ាងណាក៏ដោយ ភ្នាក់ងារនគរបាល ឬអាជ្ញាធរដទៃទៀតត្រូវចងចាំថាបុគ្គលទាំងនោះជាតំណាងផ្លូវការរបស់រដ្ឋាភិបាលបរទេស ដែលមានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិគ្រប់គ្រាន់រួចផុតពីអំណាចតុលាការនិងអាជ្ញាធរយើង។ ការលើកឡើងខាងលើនេះ ពុំមែនបានសេចក្តីថាអាជ្ញាធរយើងត្រូវឈរអោបដៃពុំមានប្រតិកម្មអ្វីសោះ ចំពោះបទល្មើសទាំងនោះទេ។ នៅពេលដែលមានឧប្បត្តិហេតុទាក់ទងទៅនឹងមន្ត្រីការទូត ឬសមាជិករបស់គេកើតឡើង ភ្នាក់ងារនគរបាលជាតិចាំបាច់ត្រូវស្រាវជ្រាវករណីនោះឱ្យបានហ្មត់ចត់ ដោយកត់ឈ្មោះនឹងលេខប័ណ្ណសំគាល់ខ្លួនរបស់អ្នកការទូតនោះ មកក្រសួងការបរទេសដើម្បីឱ្យក្រសួងធ្វើការពិចារណានឹងចាត់វិធានការសមស្របដូចជាការផ្តល់ដំណឹង ទៅស្ថានទូតសាមីជន។

ក្នុងការអនុវត្តជាក់ស្តែងមួយចំនួន កាលណាមន្ត្រីការទូតណាម្នាក់បានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរណាមួយនៅក្នុងរដ្ឋម្ចាស់ផ្ទះរដ្ឋដាក់ទូតដែលបានបញ្ជូនមន្ត្រីការទូតនោះមកជាតំណាងខ្លួននោះ តែងធ្វើការកោះហៅត្រឡប់ទៅរដ្ឋដាក់ទូតវិញ ដែលនៅទីនោះតុលាការរបស់រដ្ឋដាក់ទូត មានសិទ្ធិអាចនឹងធ្វើការចោទប្រកាន់ ឬបើកសវនាការជំនុំជម្រះ លើរឿងក្តីព្រហ្មទណ្ឌដែលមន្ត្រីការទូតបានប្រព្រឹត្តដែលអាចឈានរហូតដល់ការបញ្ឈប់មុខងារ ឬដាក់ពន្ធនាគារមន្ត្រីរូបនោះ។ ក្នុងករណីបែបណាក៏ដោយ ទោះបីជារដ្ឋដាក់ទូតកោះហៅក្តីឬពុំបានកោះហៅមន្ត្រីការទូតនោះឱ្យត្រឡប់ទៅវិញក្តី រដ្ឋម្ចាស់ផ្ទះមានសិទ្ធិជូនដំណឹងទៅស្ថានទូតមន្ត្រីនោះគ្រប់ពេលវេលា ដោយប្រកាសអ្នកការទូតនោះជា **ជនដែលពុំគួរស្វាគមន៍** Persona non Grata[36] ដើម្បីបង្ខំឱ្យគេចាកចេញពីទឹកដីរបស់រដ្ឋម្ចាស់ផ្ទះនេះ។[37] ចំពោះករណីដែលជនជាប់សង្ស័យនោះជាសមាជិកដទៃទៀតរបស់បេសកកម្មការទូត ដូចជាបុគ្គលិករដ្ឋបាល (អ្នករត់សំបុត្រ) ឬបុគ្គលិកបច្ចេកទេស (ជាងភ្លើង) រដ្ឋម្ចាស់ផ្ទះ អាចប្រកាសពួកគេពេលណាក៏បានជាបុគ្គលដែលមិនអាចទទួលយកបាន (not acceptable)។ ជាញឹកញាប់រដ្ឋម្ចាស់ផ្ទះតែងដាក់កំហិត កំណត់ឱ្យមន្ត្រីការទូត ដែលប្រព្រឹត្តបទល្មើសនោះ ចាកចេញឱ្យផុតពីទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ ក្នុងរយៈពេលមួយជាក់លាក់ដូចជា ៣ថ្ងៃ ៧ថ្ងៃ ឬ១៤ថ្ងៃ អាស្រ័យទៅតាមទំហំ ឬកម្រិតធ្ងន់ស្រាលនៃបទព្រហ្មទណ្ឌដែលមន្ត្រីការទូតនោះបានប្រព្រឹត្ត។ ក្នុងគោលបំណងរក្សាចំណងមិត្តភាពល្អ រវាងរដ្ឋម្ចាស់ផ្ទះនឹងរដ្ឋដាក់ទូតក្នុងករណីជាក់ស្តែងខ្លះ រដ្ឋម្ចាស់បានចៀសវាងមិនចាត់វិធានការ persona non grata ចំពោះមន្ត្រីការទូតរបស់រដ្ឋដាក់ទូតទេ ទោះបីជាបទល្មើសដែលមន្ត្រីការទូតនោះ បានប្រព្រឹត្តមានលក្ខណៈធ្ងន់ធ្ងរក៏ដោយ។

ជាឧទាហរណ៍ ប្រទេសកម្ពុជាបានបណ្តេញលោក Karob Palawatwichai លេខាទូតទី១ របស់ប្រទេសថៃប្រចាំនៅក្នុងប្រទេសកម្ពុជា ហើយភាគីថៃក៏បានបណ្តេញលោក សេង លីណា លេខាទូតទី១ របស់ប្រទេសកម្ពុជាប្រចាំនៅប្រទេសថៃឲ្យចាកចេញពីប្រទេសរៀងៗខ្លួនក្នុងរយៈពេល៤៨ម៉ោង ។[38]

## ៦. សុពលភាពនៃអភ័យឯកសិទ្ធិ

សុពលភាពអភ័យឯកសិទ្ធិ មានលក្ខខ័ណ្ឌដូចគ្នាទៅនឹង សុពលភាពបុព្វសិទ្ធិដែរ។

---

[36] អនុសញ្ញាទីក្រុងវ៉ៀនស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ មាត្រា៩ A receiving state may "at any time and without having to explain its decision" declare any member of a diplomatic staff *persona non grata*.

[37] ដូចចំណុច[36]

[38] គេហទំព័រព័ត៌មាន VOA ក្រោមចំណងជើង "កម្ពុជាមិនលើកទំនាស់កម្ពុជា-ថៃក្នុងកិច្ចប្រជុំអាស៊ាន-អាមេរិកទេ" ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩។ ចូលអានថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១។ តំណភ្ជាប់ https://khmer.voanews.com/a/a-40-2009-11-13-voa3-90179552/1141492.html

អភ័យឯកសិទ្ធិទាំងឡាយសម្រាប់មន្ត្រីការទូត ដូចមានចែងក្នុងអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១ មានអនុភាពចាប់ពីពេលមន្ត្រីការទូតទាំងនោះ មានធ្វើដំណើរមកដល់ទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ឬពេលដែលគេកាន់កាប់មុខតំណែង ឬប្រសិនបើជននោះស្ថិតក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះស្រាប់ អភ័យឯកសិទ្ធិទទួលបាននៅពេលមានការតែងតាំងជាផ្លូវការ (ជាលាយលក្ខណ៍អក្សរ ទៅកាន់ក្រសួងការបរទេស ឬទៅកាន់ក្រសួងណាមួយដែលបានព្រមព្រៀងគ្នា) រហូតដល់ មុខងាររបស់គេត្រូវបានបញ្ចប់និងចាកចេញផុតអំពីទឹកដីនៃរដ្ឋម្ចាស់ផ្ទះ។

ក្នុងករណីមានជម្លោះយោធា ក៏អភ័យឯកសិទ្ធិមន្ត្រីការទូតនៅតែបន្តមានរហូតដល់ពេលខាងលើ។

រីឯករណី មានមរណភាពចំពោះ មន្ត្រីការទូតក្តី សមាជិកគ្រួសារនៃមន្ត្រីការទូត(ដែលស្នាក់នៅក្នុងរដ្ឋម្ចាស់ផ្ទះ)ក្តី គេនៅទទួលបានអភ័យឯកសិទ្ធិពេញលេញរហូតដល់ចាកចេញផុតពីដែនដីរបស់រដ្ឋម្ចាស់ផ្ទះ។

# សេចក្ដីសន្និដ្ឋាន

តាមរយៈការបកស្រាយអំពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិអ្នកការទូតបានបង្ហាញឱ្យឃើញថា ការទូតជាចំណែកមួយយ៉ាងសំខាន់ចំពោះទំនាក់ទំនងអន្តរជាតិ មិនថារវាងរដ្ឋម្ចាស់ផ្ទះ ឬរដ្ឋដាក់ទូត ដែលយើងសង្កេតឃើញថាជាប្រព័ន្ធមួយដែលធ្វើឱ្យទំនាក់ទំនងនៃរដ្ឋនិងរដ្ឋមានភាពស្និតស្នាល នឹងបំពេញមុខងារជាអ្នកតំណាងនៃរដ្ឋនីមួយៗដែលបានដាក់ទូតក្នុងការសម្របសម្រួល ឬដោះស្រាយបញ្ហា ដែលនឹងមានការធានាដល់ទំនាក់ទំនងនៃរដ្ឋទាំងពីរ។ ដូចដែលបានរៀបរាបខាងលើ ទំនាក់ទំនងអន្តរជាតិគឺជាប្រព័ន្ធមួយដែលសំខាន់សម្រាប់រដ្ឋនីមួយៗក្នុងការទំនាក់ទំនងគ្នា ដោយយោងតាមបទដ្ឋានអន្តរជាតិនានាដែលក្នុងនោះរួមមានអនុសញ្ញាទីក្រុងវៀនស្ដីពីទំនាក់ទំនងការទូតជាគោល។ តាមការបកស្រាយខាងលើយើងសង្កេតឃើញថា ការផ្ដល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិដល់អ្នកការទូតគឺជា ការការពារមួយនិងជាការផ្ដល់កិត្តិយសដល់រដ្ឋដែលបានដាក់ទូតក្នុងនាមជារដ្ឋអធិបតេយ្យ ដែលទោះជាមានបញ្ហាមួយចំនួនក៏ដោយក៏មិនអាចបំពារបំពានបាន។ ទោះបីជាមានប្រទេសមួយចំនួនមិនបានអនុវត្តពេញលេញទៅតាមអនុសញ្ញាចែងក៏ដោយ ក៏វាមានប្រសិទ្ធិភាពដែលអាចជួយសម្របសម្រួលដល់អ្នកបំពេញបេសកកម្មការទូតទាំងនោះមិនឱ្យមានការគាបសង្កត់ពីរដ្ឋម្ចាស់ផ្ទះដោយប្រការណាមួយ។ ដោយតាមការបកស្រាយខាងលើ យើងអាចឃើញនូវចំណុចជាច្រើនដែលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិនេះផ្ដល់ជាអត្ថប្រយោជន៍ដូចជា លិខិតឆ្លងដែនការទូតដែលមានលក្ខណៈខុសពីលិខិតឆ្លងដែនធម្មតា រួមទាំងសិទ្ធិដែលមិនអាចបំពារបំពានបាននៃអ្នកការទូតអាចរួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះ។ ដោយមានការផ្ដល់សិទ្ធិទាំងនេះហើយ ធ្វើឱ្យអ្នកបម្រើការបេសកកម្មការទូតនេះមានភាពងាយស្រួលជាងអ្នកដែលគ្មានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងនេះ។

ដូចនេះការផ្ដល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិដល់អ្នកការទូត គឺជាការផ្ដល់ឱ្យនូវប្រទេសដាក់ទូតនូវកិត្តិយសដែលជាតំណាងនៃប្រទេសនោះដើម្បីជាអ្នកតំណាងដល់រដ្ឋឬជាអ្នកតំណាងឱ្យពលរដ្ឋខ្លួនដែលទៅធ្វើការឬរៀននៅប្រទេសម្ចាស់ផ្ទះ ដោយជាអ្នកអាណាព្យាបាលនៃពួកគេទាំងនោះនិងដោះស្រាយបញ្ហាផ្សេង។ ការផ្ដល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិវាអាចធ្វើឱ្យមន្ត្រីដែលត្រូវបំពេញការងារមានសិទ្ធិគ្រប់គ្រាន់និងងាយស្រួលក្នុងការបំពេញការងារដោយគ្មានការភ័យខ្លាច ថានឹងប៉ះពាល់ដល់ច្បាប់មួយចំនួននៃរដ្ឋម្ចាស់ផ្ទះ ។ បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិដែលបានផ្ដល់ឱ្យអ្នកការទូតនិងបុគ្គលិកមន្ត្រីរួមទាំងគ្រួសាររបស់គេនេះ វាក៏ជាផលប្រយោជន៍មួយសម្រាប់សមាជិកនៃរដ្ឋដាក់ទូតនិងអាចឱ្យពួកគេមានសិទ្ធិ ព្រមទាំងផលប្រយោជន៍មួយចំនួនដែលមិនភ័យខ្លាចក្នុងការរស់នៅនិងធ្វើការនៅប្រទេសក្រៅពីប្រទេសកំណើត។ ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាយើងក៏បានដាក់ឱ្យសិក្សានូវមុខវិជ្ជានេះដើម្បីជាប្រយោជន៍មួយសម្រាប់ការទំនាក់ទំនងទៅនិងប្រទេសដទៃ ដែលក្នុងការទំនាក់ទំនងនេះយើងអាច

មើលឃើញថាមានប្រទេសដែលបានដាក់ទូតបានផ្តល់ប្រយោជន៍ច្រើន ពិសេសលើការធ្វើពាណិជ្ជកម្មនិងលើវិស័យអប់រំ។

# អនុសាសន៍

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ យើងខ្ញុំយល់ឃើញថា បទបញ្ញត្តិច្បាប់មួយចំនួន ដែលពាក់ព័ន្ធនឹងប្រធានបទទំនាក់ទំនងការទូតនៅមានចន្លោះខ្វះខាតនៅឡើយ។ ជាពិសេស ឯកសារអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតនៅពុំទាន់មានបកប្រែជាភាសាជាតិផ្លូវការនោះទេ។ មួយវិញទៀត ពាក់ព័ន្ធនឹងបញ្ហាស្រាវជ្រាវឯកសារតាមប្រព័ន្ធអ៊ីធឺណែតមានភាពលំបាកណាស់។ បើទោះបីជាបច្ចុប្បន្ន គេឃើញមានសន្ទុកនៃការចងក្រងឯកសារទាំងអស់នោះតាមកម្មវិធីអ៊ែប(app) ប៉ុន្តែនៅមានកម្រិតនៅឡើយ ដោយភាគច្រើនមានតែឯកសារច្បាប់ធំៗដូចជា រដ្ឋធម្មនុញ្ញជាដើម។

ដោយសារកត្តាទាំងអស់នេះ ព្រមទាំងដើម្បីជាប្រយោជន៍ដល់សិស្សនិស្សិតជំនាន់ក្រោយ ដែលមានបំណងសិក្សាស្រាវជ្រាវលើប្រធានបទទាក់ទងនឹងការទូត យើងខ្ញុំសូមផ្តល់ជាមតិយោបល់មួយចំនួន។ ដូចបានរៀបរាប់ខាងលើ អំពីកង្វះខាតឯកសារផ្លូវច្បាប់ជាភាសាជាតិ យើងខ្ញុំសំណូមពរឱ្យថ្នាក់ដឹកនាំ រដ្ឋសភា ព្រឹទ្ធសភា ព្រមទាំងក្រសួងពាក់ព័ន្ធដទៃទៀតៈ

- ចំពោះការអនុវត្តបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសម្រាប់បណ្តាប្រទេសដែលជាសមាជិកនៃអនុសញ្ញាទីក្រុងវៀនស្តីពីការទូតនេះនៅមានចំនុចខ្វះចន្លោះ ដូចជាការមិនគោរពតាមអភ័យឯកសិទ្ធិដែលបានផ្តល់ឱ្យទៅអ្នកបំពេញបេសកកម្មការទូតដូចជាការបង្កអោយមានរបួសស្នាម ឬគ្រោះថ្នាក់ដល់ជីវិតផងដែរ។ មួយវិញទៀតចំពោះការផ្តល់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដល់ភ្នាក់ងារការទូតនេះក៏ជាគុណសម្បត្តិ នឹងជាគុណវិបត្តិមួយតូចសម្រាប់ប្រទេសមួយចំនួនដែលមិនគោរពតាមអ្វីដែលអនុសញ្ញាបានចែង ដែលអាចធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ដល់រដ្ឋម្ចាស់ផ្ទះផងដែរ។ សម្រាប់រដ្ឋមួយចំនួនមានការគោរពនិងចំពោះរដ្ឋខ្លះមានការបំពានហើយថែមទាំងយក បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិមកធ្វើជាលេះដើម្បីការពារដល់ការប្រព្រឹត្តល្មើសរបស់ខ្លួន។ ទោះបីជាមិនមានករណីច្រើនក៏ដោយ ក៏មានភាពអយុត្តិធ៌មចំពោះជនរងគ្រោះ ដូចច្នេះសូមអោយរដ្ឋមួយចំនួនហ្នឹងធ្វើការគោរពតាមអនុសញ្ញាតែមិនមែនយកបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនេះយកមកប្រព្រឹត្តអំពើល្មើសឡើយ។
- សម្រេចធ្វើការចងក្រងអនុសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូតបកប្រែជាភាសាជាតិជាផ្លូវការមួយសម្រាប់សម្រួលដល់ការសិក្សា ស្វែងយល់និងស្រាវជ្រាវពីសំណាក់បញ្ញវ័ន្តដទៃទៀត។ ដោយហេតុថាកម្ពុជាបានចូលជាភាគីនៃអនុសញ្ញាតាំងតែងពីឆ្នាំ១៩៦៣មកម្ល៉េះ ប៉ុន្តែប្រទេសយើងនៅពុំទាន់អនុវត្តតាមនីតិវិធីផ្តល់សច្ចាប័នបានគ្រប់ជ្រុងជ្រោយនោះទេ។ ហេតុដូចនេះ ស្នើឱ្យមានការបកប្រែអនុសញ្ញាជាភាសាខ្មែរដោយអង្គនីតិបញ្ញត្តិ ព្រមទាំងអនុម័តសម្រេចទទួល និងចុងក្រោយដាក់ចេញឱ្យប្រើប្រាស់ដោយព្រះរាជក្រម។

– បន្ថែមពីនេះដែរ ក្រោយពេលស្ថានការជម្ងឺរាតត្បាតមានភាពធូរស្រាលទៅ ក្នុងនាមជានិស្សិតយើងខ្ញុំសំណូមពរ ឱ្យរាជរដ្ឋាភិបាលសម្រេចពិចារណា ចងក្រងរាល់ឯកសារ បទបញ្ញត្តិច្បាប់ជាតិ សន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ វិធានការ សេចក្តីសម្រេច សារាចរ សៀវភៅនិពន្ធនានាក្នុងប្រព័ន្ធអេឡិចត្រូនិចជាប្រភេទគេហទំព័រផ្លូវការរបស់ជាតិ ឬជាប្រភេទបណ្ណាល័យអេឡិចត្រូនិចរបស់ជាតិ។ ដោយក្នុងមាតិកានៃបណ្ណាល័យអេឡិចត្រូនិចរបស់ជាតិនោះចាប់ពី ច្បាប់ជាតិ-អន្តរជាតិនានា រហូតដល់សៀវភៅកំសាន្ត ប្រលោមលោកជាតិ-អន្តរជាតិ។ បែបនេះ ទើបអាចជួយសម្រួលទៅដល់អ្នកស្រាវជ្រាវគ្រប់កម្រិតសិក្សា ព្រមទាំងលើកកម្ពស់ការអានចំពោះប្រជាពលរដ្ឋគ្រប់វ័យថែមទៀតផង។

# ឯកសារយោង


## ឯកសារជាសៀវភៅ

- ស៊ា កុសល. "ច្បាប់ការទូត (Diplomatic law/Droit Diplomatique)" ឆ្នាំ១៩៩៩។
